# បរិយាកាស និងទម្លាប់នៃការអាន របស់សិស្ស

ថ្នាក់ទី 4 ដល់ 6



របាយការណ៍ស្ទង់មតិ

ប្រទេសកម្ពុជា - ខែ កញ្ញា ឆ្នាំ ២០១៦

World Vision

# សេចក្តីថ្លែងអំណរគុណ

របាយការណ៍ស្ទង់មតិនេះអាចរៀបចំឡើងបានដោយសារមានការគាំទ្រយ៉ាងពេញទំហឹងពីដៃគូភាគីពាក់ព័ន្ធ និងក្រុមការងាររបស់យើង។ យើងខ្ញុំសូមថ្លែងអំណរគុណជាពិសេសដល់សិស្សថ្នាក់ទី4 ដល់ថ្នាក់ទី6 ទាំងអស់ដែលមកពីខេត្តគោលដៅទាំងប្រាំបួនរបស់អង្គការទស្សនៈពិភពលោក ដែលមានឆន្ទៈចូលរួមយ៉ាងសកម្មនៅក្នុងការសិក្សានេះ ព្រមទាំងបានផ្តល់ព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងបទពិសោធន៍ និងទម្លាប់នៃការអានរបស់ខ្លួន។ យើងខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះក្រសួងអប់រំ យុវជន និងកីឡា ជាពិសេសនាយកសាលាក៏ដូច ជាគ្រូបង្រៀននៅក្នុងបណ្តាខេត្តគោលដៅទាំងអស់។ ប្រសិនបើគ្មានការជួយជ្រោមជ្រែងពីសំណាក់ពួកគេនោះទេ របាយការណ៍នេះមិនអាចលេចចេញជារូបរាងបានឡើយ។ ការជួយគាំទ្រ និងកិច្ចសហការជាប្រចាំរបស់ពួកគេមានសារសំខាន់ណាស់ចំពោះការសម្រេចគោលដៅរបស់យើងក្នុងការធានាគុណភាពអប់រំ សម្រាប់កុមារកម្ពុជា។ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះលោក **Seng Krisna** ដែលជាអ្នកប្រឹក្សាឯករាជ្យ ក៏ដូចជាក្រុមប្រមូល ទិន្នន័យផងដែរ។ របាយការណ៍នេះពឹងផ្អែកទាំងស្រុងទៅលើទិន្នន័យប្រកបដោយគុណភាព និងការវិភាគ ទិន្នន័យជំហ៊ានបឋម។

ជាចុងក្រោយ យើងខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលិករបស់យើងនៅតំបន់ប្រតិបត្តិទាំង9 នៅផ្នែកតស៊ូមតិ និងកម្មវិធីអប់រំនិងបំណិនជីវិតដែលធានាឲ្យមានការសម្របសម្រួលដោយរលូន និងធានាថា ការស្ទង់មតិត្រូវបានធ្វើឡើងប្រកបដោយគុណភាព និងក្នុងលក្ខណៈដែលមានសុវត្ថិភាពចំពោះកុមារ។

**ការសិក្សានេះមានការសម្របសម្រួលពីសំណាក់**
Lyda Chea, Jill-Kila Reimer (Ph.D), Steve Cooke and Rithy Prum.

# សេចក្តីប្រកាសបដិសេធ និងការបញ្ជាក់កម្មសិទ្ធបញ្ញារបស់របាយការណ៍

លទ្ធផលរកឃើញនៅក្នុងរបាយការណ៍នេះគឺផ្អែកទៅលើការស្ទាបស្ទង់មតិដែលបានធ្វើឡើងកាលពីខែកក្កដា ឆ្នាំ 2016។ ធនធានអំណាននៅតាមសាលា និងនៅតាមផ្ទះអាចកើនឡើង ឬថយចុះក្រោយការប្រមូលទិន្នន័យ។ របាយការណ៍នេះបង្ហាញលទ្ធផលលើបទពិសោធន៍ ទម្លាប់ និងបរិយាកាសនៃការអានរបស់សិស្សបឋមសិក្សា។ របាយការណ៍នេះរៀបចំឡើងដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃកម្មវិធីអប់រំនិងបំណិនជីវិត ព្រមទាំងជួយគាំទ្រការធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងៗទៀតសម្រាប់ការផ្លាស់ប្តូរដែល នឹងជួយលើកកម្ពស់ការអប់រំកុមារគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។

**ឯកសារយោង៖**

World Vision International (2016). Reading Environments and Habits of Students in Grades 4 to 6. Survey Report. Phnom Penh: Cambodia.

រក្សាសិទ្ធិគ្រប់យ៉ាង © ខែកញ្ញា ឆ្នាំ2016 ដោយអង្គការទស្សនៈពិភពលោក

# អំពីអង្គការទស្សនៈពិភពលោក

ព័ន្ធកិច្ចរបស់អង្គការទស្សនៈពិភពលោកគឺផ្តោតទៅលើការលើកកម្ពស់ជីវិតរស់នៅរបស់កុមារក្រីក្របំផុត និងគ្រួសាររបស់ពួកគេនៅក្នុងប្រទេសកម្ពុជា។ យើងធ្វើការជាដៃគូជាមួយកុមារ និងយុវជន គ្រួសារ និងសហគមន៍របស់ពួកគេ ដែលមកពីគ្រប់ជំនឿ សាសនា ភេទ ជាតិពិន្ទុ ព្រមទាំងគ្រប់និន្នាការនយោបាយ។

យើងមានបំណងដើម្បីផ្តល់សិទ្ធិអំណាចដល់បុគ្គលិករបស់យើង និងសហគមន៍ដែលយើងបម្រើ នៅក្នុងការចូលរួមកសាងអនាគតកាន់តែប្រសើរសម្រាប់កុមារកម្ពុជា។ អនាគតនេះរួមមាន "ជីវិតពេញបរិបូរណ៍" និងឆន្ទៈអនុវត្តការងារដែលប្រែក្លាយសមាជិកសហគមន៍ ដោយធ្វើឲ្យគ្រួសារកាន់តែរឹងមាំ និងកាន់តែមានលទ្ធភាពតស៊ូនឹងភាពមិនច្បាស់លាស់នៃស្ថានភាពសេដ្ឋកិច្ច។

តាមរយៈវិធីសាស្រ្តពេញលេញ និងរួមបញ្ចូលគ្នា យើងអាចសម្រេចបាននូវអាទិភាពជាយុទ្ធសាស្រ្តនៃសុខុមាលភាពកុមារ ដែលផ្តោតការលើកកម្ពស់ ស្ថានភាពអាហារូបត្ថម្ភរបស់កុមារនៅក្នុងរយៈពេល 1000ថ្ងៃ ដំបូងនៃជីវិត ការអប់រំថ្នាក់បឋមសិក្សាដែលជំរុញការសិក្សាប្រកបដោយគុណភាព ការទប់ស្កាត់ និងការពារកុមារពីការរំលោភបំពាន និងការកេងប្រវ័ញ្ច ព្រមទាំងការជួយត្រៀមយុវជនឲ្យមានគំនិតច្នៃប្រឌិត ក្លាយជាពលរដ្ឋសកម្ម និងជាអ្នកដឹកនាំនៅថ្ងៃស្អែកផងដែរ។

## ទស្សនៈវិស័យ

**ទស្សនៈវិស័យរបស់យើង គឺចង់ឃើញកុមារគ្រប់រូបមានជីវិតពេញបរិបូរណ៍។**
**សេចក្តីអធិស្ឋានរបស់យើង សូមឲ្យទឹកចិត្តគ្រប់រូបមានឆន្ទៈដើម្បីសម្រេចបំណងនេះ។**

# មាតិការ


សេចក្តីថ្លែងអំណរគុណ 2

សេចក្តីប្រកាសបដិសេធ និងការបញ្ជាក់កម្មសិទ្ធបញ្ញារបស់របាយការណ៍ 2

អំពីអង្គការទស្សនៈពិភពលោក 3

សេចក្តីសង្ខេប 6

អនុសាសន៍ 8

១. សេចក្តីផ្តើម

១.១ អំពីកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោក 9

១.២ សារតារ និងគោលបំណងនៃការសិក្សា 9

២. វិធីសាស្ត្រស្រាវជ្រាវ

២.១ ការជ្រើសរើសគំរូសិក្សា 11

២.២ ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ 12

២.៣ ការបញ្ចូល និងការវិភាគទិន្នន័យ 12

២.៤ ភាពកំណត់របស់ការសិក្សា 13

វិសាលភាពនៃការសិក្សា 14

៣. លទ្ធផលនៃការសិក្សា

៣.១ កម្រងទិន្នន័យប្រជាសាស្ត្ររបស់សិស្សដែលបានសិក្សា 15

៣.២ បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសអាននៅផ្ទះ 16

៣.៣ បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសអាននៅតាមសាលា 19

៣.៤ ទម្លាប់អានសៀវភៅរបស់សិស្ស 25

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

សង្ខេបលទ្ធផល 34

អនុសាសន៍ 37

# សេចក្តីសង្ខេប

ជាផ្នែកមួយនៃយុទ្ធសាស្រ្តថ្មីរបស់ កម្មវិធីអប់រំ និងបំណិនជីវិតរបស់អង្គការទស្សនៈពិភពលោក (WV) នៅក្នុងប្រទេសកម្ពុជាគឺបានធ្វើការវាយតម្លៃជាបន្តបន្ទាប់នៅតាមបណ្តាខេត្តគោលដៅទាំងប្រាំបួនរបស់ WV នៅក្នុងឆ្នាំ 2016។ ការសិក្សាដំបូងបានផ្តោតទៅលើធនធានអំណានដែលកុមាររកបាននៅតាមសាលាបឋមសិក្សាដោយធ្វើការវិភាគទៅលើស្ថានភាពបណ្ណាល័យ និងប្រៀបធៀបជាមួយស្តង់ដារថ្នាក់ជាតិសម្រាប់បណ្ណាល័យបឋមសិក្សា (គអយក 2011)។ ការសិក្សានេះត្រូវបានធ្វើឡើងបន្ទាប់ពីការសិក្សាទៅលើបណ្ណាល័យនេះ និងជាការសិក្សាបែបបរិមាណអំពីបទពិសោធន៍ ទម្លាប់ និង បរិយាកាសនៃការអានរបស់សិស្សចំនួន 507នាក់ ចាប់ពីថ្នាក់ទី 4 ដល់ថ្នាក់ទី 6 (ពីសាលាចំនួន 39 នៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ កណ្តាល ព្រះវិហារ តាកែវ និងសៀមរាប)។

គោលបំណងនៃការសិក្សានេះគឺដើម្បីជួយ WV ក្នុងការបង្កើតយុទ្ធសាស្រ្តកាន់តែប្រសើរដែលនឹងជួយបង្កើនប្រសិទ្ធភាពនៃកម្មវិធីអប់រំ និងជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជាក៏ដូចជាភាគីពាក់ព័ន្ធផ្សេងៗទៀត ដើម្បីធ្វើការផ្លាស់ប្តូរដែលនឹងជួយលើកកម្ពស់ការអប់រំកុមារគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។ ការសិក្សានេះរកឃើញលទ្ធផលសំខាន់ៗជាច្រើន។ ទោះជាយ៉ាងនេះក្តី ក៏នៅមានបញ្ហារាំងស្ទះមួយចំនួនផងដែរ។ បញ្ហាសំខាន់ចម្បងរួមមាន ការលំបាកនៅក្នុងការជ្រើសរើសសិស្សដោយសារ "វេន" សិក្សាខុសៗគ្នានៅតាមសាលាបឋមសិក្សា បញ្ហាប្រឈមនៅក្នុងការទៅឲ្យដល់សាលារៀនមួយចំនួនបន្ទាប់ពីទឹកភ្លៀងបានបង្កឲ្យមានការលំបាក និងស្ថានភាពផ្លូវ ព្រមទាំងចំនួនសាលាដែលគ្មានបណ្ណាល័យមានចំនួនតិចជាងតួលេខដែលបានគ្រោងពីដំបូង។

លទ្ធផលរកឃើញ និងសេចក្តីសន្និដ្ឋានសំខាន់ៗមានសង្ខេបជូនដូចខាងក្រោម៖

## ១. បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសនៃការអាននៅតាមផ្ទះ

សិស្សបានរៀបរាប់ថា ម្តាយ និងឪពុករបស់ខ្លួនគឺជាមនុស្សសំខាន់ទីពីរ និងទីបីដែលជួយខ្លួនក្នុងការអាន និង សរសេរ នៅពេលខ្លួននៅតូច (66% និង 61%) គ្រូបង្រៀនគឺជាបុគ្គលមានសារៈសំខាន់បំផុត (72%)។ សិស្សស្ទើរតែទាំងអស់ (94%) បាននិយាយថា សមាជិកគ្រួសារ "តែងតែលើកទឹកចិត្ត" ខ្លួនឲ្យអានសៀវភៅ និង74.4% បាននិយាយថា សមាជិកគ្រួសារ "តែងតែអាន" សៀវភៅរឿង ឬសៀវភៅផ្សេងៗឲ្យខ្លួនស្តាប់។

ការសិក្សាបានបង្ហាញថា ការអនុវត្តល្អនៅតាមផ្ទះទាំងនេះ (ទម្លាប់នៃការអានក្នុងគ្រួសារ) ទាំងបច្ចុប្បន្ននិងនៅពេលសិស្ស នៅតូច (ដូចជាការអានសៀវភៅរឿងឲ្យសិស្សស្តាប់ ជួយពួកគេធ្វើកិច្ចការសាលា) អាចមានឥទ្ធិពលទៅលើការយល់ឃើញ និងភាពចូលចិត្តអានរបស់កុមារ។ ទាំងការអានឲ្យកុមារស្តាប់នៅវ័យកុមារភាព និងការលើកទឹកចិត្តឲ្យកុមារអាននៅវ័យកុមារភាពនាំឲ្យសិស្សកាន់តែអានញឹកញាប់ និងកាន់តែចូលចិត្តអាន។ លទ្ធផលរកឃើញទាំងនេះផ្តល់នូវភ័ស្តុតាងកាន់តែច្បាស់ដែលបង្ហាញថា ការលើកកម្ពស់ទម្លាប់នៃការអានក្នុងគ្រួសារគួរតែជាធាតុសំខាន់នៃកម្មវិធីអក្ខរកម្ម។

សៀវភៅពុម្ពគឺជាឯកសារអាននៅតាមផ្ទះដែលងាយរកបានបំផុត ដោយមានសិស្សស្ទើរតែទាំងអស់ (98%)បាន រៀបរាប់ថា មានសៀវភៅពុម្ពយ៉ាងតិចណាស់មួយក្បាល។ សិស្សចំនួនប្រហែលពាក់កណ្តាល (53.6%) បានរៀបរាប់ថាមានសៀវភៅរឿង ស្របពេលដែលមានសិស្សតិចតួចដែលបានរៀបរាប់ថាមានឯកសារអានប្រភេទផ្សេងៗទៀតនៅតាមផ្ទះ។ ដើម្បីជួយបង្កើនជំនាញអានរបស់ខ្លួន សិស្សបានសំណូមពរឲ្យគ្រួសារជួយគាំទ្រ និងយកចិត្តទុកដាក់ចំពោះខ្លួនឲ្យបានខ្លាំងក្លា ព្រមទាំងចំណាយពេលវេលាបង្រៀនកុមារឲ្យបានទៀងទាត់ ជួយកុមារក្នុងការប្រកបអក្សរ និងជួយសម្រួលកុមារក្នុងការមកសាលាឲ្យបានទៀងទាត់។

## ២. បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសនៃការអាននៅសាលា ជាពិសេសនៅបណ្ណាល័យ

នៅសាលា សិស្សជាច្រើនបានរៀបរាប់ថាបានទទួលជំនួយពីគ្រូដែលបានបង្រៀនខ្លួនអំពីសំឡេងអក្សរ និងពាក្យ (93%) និងអានសៀវភៅផ្សេងៗឮៗឲ្យខ្លួនស្តាប់ (68.8%)។ ក្រៅពីនេះ សិស្សចំនួន 77% យល់ឃើញថាជំនួយរបស់គ្រូ " មានប្រយោជន៍ខ្លាំង" ចំណែក 22.7% យល់ឃើញថា "មិនសូវជាមានប្រយោជន៍ទេ"។ ចំនួន 85% នៃសិស្សទាំងអស់មកពីសាលាចំនួន 32 បានរៀបរាប់ថាមានបណ្ណាល័យមួយនៅក្នុងសាលារបស់ខ្លួន។ ប៉ុន្តែដោយផ្អែកលើការរៀបរាប់របស់សិស្សអំពីថ្ងៃ និងម៉ោងបើកបណ្ណាល័យ ការសិក្សាបានបង្ហាញថា បណ្ណាល័យជាច្រើនបើកដំណើរការមិនទៀងទាត់ឡើយ។ ជាក់ស្តែង បន្ទាប់ពីធ្វើតេស្តស្ថិតិរកទំនាក់ទំនងបានបង្ហាញថា បណ្ណាល័យដែលបើករយៈពេល 1, 2 ឬ 3 ថ្ងៃក្នុងមួយសប្តាហ៍ក៏ទំនងជា បើក តិចម៉ោងក្នុងមួយថ្ងៃផងដែរ។

ភាពញឹកញាប់នៃការចូលអានសៀវភៅនៅបណ្ណាល័យរបស់សិស្សក៏មានលក្ខណៈខុសៗគ្នាគួរឲ្យកត់សម្គាល់ផងដែរដោយមានសិស្សចំនួន 16% មិនដែលចូលអានសៀវភៅក្នុងបណ្ណាល័យសោះនៅក្នុងសប្តាហ៍មុនការសិក្សា។ ក្រៅពីនេះ អត្រាសិស្សខ្ចីសៀវភៅពីបណ្ណាល័យមានកម្រិតទាបខ្លាំង ដោយមានចំនួន 45.2% មិនធ្លាប់ខ្ចីសៀវភៅពីបណ្ណាល័យឡើយ នៅក្នុងឆ្នាំនេះ។ ជាក់ស្តែង សេវាខ្ចីសៀវភៅបានទទួលភាពពេញចិត្តតិចតួចបំផុតដោយមានចំនួន 25% បានរៀបរាប់ថា "មិនសូវពេញចិត្ត"។ មូលហេតុសំខាន់គឺថា សិស្សមានកង្វល់យ៉ាងខ្លាំងអំពីការបាត់បង់ ឬខូចខាតសៀវភៅ ជាការយល់ឃើញស្រដៀងគ្នារបស់បណ្ណារក្ស និង/ ឬគ្រូបង្រៀន។

ទោះបីបរិយាកាសនៃការអាននៅតាមសាលាមិនមែនសំដៅលើបណ្ណាល័យក៏ដោយ បញ្ហាជាច្រើនដែល (អាច) ធ្វើឲ្យសិស្សមិនចង់អានសៀវភៅនៅសាលាទំនងជាពាក់ព័ន្ធនឹងគុណភាពទាបនៃស្តង់ដារបណ្ណាល័យដែលមានបញ្ជាក់នៅក្នុងគោលនយោបាយ "ស្តង់ដារបណ្ណាល័យ បឋមសិក្សា" របស់ ក្រសួងអប់រំ យុវជននិងកីឡា (ឆ្នាំ 2011)។ អ្វីដែលជាសំណូមពរសំខាន់របស់សិស្សក្នុងការជួយកែលម្អបរិយាកាសអាននៅតាមសាលា គឺការធ្វើឲ្យមានស្តង់ដារបណ្ណាល័យទាំងនេះ។ ដូច្នេះការវិនិយោគ និងការគាំទ្របន្ថែមដល់សាលាដើម្បីបំពេញតាមស្តង់ដារទាំងនេះ អាចជួយកែលម្អទម្លាប់ នៃការអានរបស់សិស្សបាន។

## ៣. ចំណង់ចំណូលចិត្ត និងទម្លាប់នៃការអានទូទៅរបស់សិស្ស

សិស្សភាគច្រើន (82%) បាននិយាយថាការ "អានសៀវភៅ" ជាសកម្មភាពកម្សាន្តក្នុងពេលទំនេរមួយរបស់ខ្លួន ហើយសិស្សភាគច្រើនអានសៀវភៅពុម្ព (96%) និងសៀវភៅរឿង (76%)។ ទោះបីជាយ៉ាងនេះក្តីប្រសិនបើមានសៀវភៅអានគ្រប់ប្រភេទសិស្សក៏បានបង្ហាញអំពីការចាប់អារម្មណ៍ក្នុងការអានសៀវភៅប្រភេទផ្សេងៗទៀតផងដែរ។ ផ្ទះគឺជាកន្លែងអានសៀវភៅដែលសិស្សចូលចិត្តបំផុតបន្ទាប់មកគឺបណ្ណាល័យនៅតាមសាលា។ ក្រៅពីសៀវភៅពុម្ព សិស្សចំណាយពេលចន្លោះពី 2 ទៅ 5 ដងក្នុងមួយសប្តាហ៍ទៅលើការអានដែលជាចំនួនល្អ ។ ប៉ុន្តែចំនួនម៉ោងអានក្នុងមួយសប្តាហ៍មានរយៈពេលខ្លីគឺប្រហែលជា 1 ម៉ោង តែប៉ុណ្ណោះ។

ជាមធ្យមសិស្សអានសៀវភៅចំនួន 12 ក្បាល នៅក្នុងរយៈពេល 12 ខែ ចុងក្រោយ ហើយវាក៏មានទំនាក់ទំនងគ្នារវាងចំនួនសៀវភៅដែលសិស្សបានអាន ទៅនឹងសាលាដែលមាន និងគ្មានបណ្ណាល័យ។ នៅតាមសាលាដែលមានបណ្ណាល័យ ចំនួនសៀវភៅដែលសិស្សបានអាននៅក្នុងមួយឆ្នាំសិក្សាមានចំនួនច្រើនជាងសាលាដែលគ្មានបណ្ណាល័យ។ វាហាក់បង្ហាញថា ការធ្វើឲ្យប្រសើរឡើងនូវប្រភេទសៀវភៅ និងខ្លឹមសារដែល សិស្សអាចរកបាន អាចមានឥទ្ធិពលជាវិជ្ជមានទៅលើទំលាប់នៃការអានរបស់សិស្ស និងជំរុញទឹកចិត្តសិស្សឲ្យអានកាន់តែញឹកញាប់ និងមានរយៈពេលយូរជាងមុន។ ការអនុវត្តពាក់ព័ន្ធនឹងការអានទាំងនេះមានសារៈសំខាន់ចំពោះការពង្រឹងជំនាញអក្ខរកម្ម និងការផ្តល់លទ្ធភាពដល់កុមារក្នុងការអភិវឌ្ឍពី "រៀនអាន" (រៀនរបៀបអានអក្សរ) ទៅជា "អានដើម្បីរៀន" (អានដើម្បីរៀនអំពីមុខវិជ្ជាអ្វីមួយដើម្បីបង្កើនចំណេះដឹង ឬជំនាញ)។

# អនុសាសន៍

ដោយផ្អែកលើលទ្ធផលរកឃើញសំខាន់ៗ អនុសាសន៍មួយចំនួនត្រូវបានស្នើឡើងចំពោះភាគីពាក់ព័ន្ធសំខាន់ៗ រួមទាំងអង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល ដើម្បីឲ្យទម្លាប់នៃការអានរបស់សិស្សអាចទទួលបានការគាំទ្រ និងកែលម្អ៖

## អនុសាសន៍សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា (កអយក):

- ធានាថា មានចំនួនបណ្ណារក្សគ្រប់គ្រាន់នៅតាមសាលារៀន ហើយបណ្ណារក្សទាំងនោះទទួលបានការបណ្តុះបណ្តាលអំពីរបៀបគ្រប់គ្រងធនធានបណ្ណាល័យឲ្យកាន់តែល្អប្រសើរនិងលើកកម្ពស់ប្រសិទ្ធិភាពបណ្ណាល័យដើម្បីជួយគាំទ្រសកម្មភាពអានរបស់សិស្ស។
- បង្កើនភាពសម្បូរបែប ប្រភេទ និងបរិមាណឯកសារសម្រាប់អាននៅតាមបណ្ណាល័យ និងធានាថា សិស្សត្រូវបានលើកទឹកចិត្តឲ្យខ្ចីសៀវភៅពីបណ្ណាល័យ។
- សម្របសម្រួលឲ្យកាន់តែល្អប្រសើរជាមួយនឹងរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិដើម្បីធានាថា ការតាមដាន សេវាសាលារៀន រួមទាំងសេវាបណ្ណាល័យ ត្រូវបានអនុវត្តជាទៀងទាត់ និងមានគោលដៅជាក់លាក់ និងការគាំទ្រចំពោះសាលាដើម្បីអាចសម្រេចបានស្តង់ដារបណ្ណាល័យ បឋមសិក្សា។

## អនុសាសន៍សម្រាប់នាយកសាលា គ្រូបង្រៀន និងគណៈកម្មាធិការទ្រទ្រង់សាលា៖

- នាយកសាលា និងគ្រូបង្រៀនគួរអនុវត្តវិធានការជាក់ស្តែងដែលលើកទឹកចិត្តសិស្សឲ្យ ប្រើប្រាស់បណ្ណាល័យសាលាកាន់តែញឹកញាប់ជាងមុន រួមទាំងការលើកទឹកចិត្តសិស្សឲ្យចំណាយពេលកាន់តែច្រើននៅក្នុងបណ្ណាល័យ និងខ្ចីឯកសារអានកាន់តែច្រើន ដើម្បីយកទៅអាននៅក្រៅបណ្ណាល័យ។
- ក្នុងករណីដែលបណ្ណាល័យមានធនធានមានកំណត់ និងមិនស្របតាមស្តង់ដារថ្នាក់ជាតិ ត្រូវស្វែងរកការគាំទ្របន្ថែមពីក្រុមប្រឹក្សាឃុំ និងការិយាល័យអប់រំស្រុកដើម្បីទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុបន្ថែមដើម្បីឲ្យកាន់តែខិតជិតស្តង់ដារ។
- ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះសកម្មភាព និងកម្មវិធីដែលមានការចូលរួមពីឪពុកម្តាយ និងអ្នកថែទាំពាក់ព័ន្ធនឹងការអប់រំកុមារ រួមទាំងការលើកទឹកចិត្តឲ្យឪពុកម្តាយអានជាមួយ/អានឲ្យកូនស្តាប់នៅផ្ទះ លើកទឹកចិត្តកុមារឲ្យខ្ចីសៀវភៅពីបណ្ណាល័យ និងទិញឯកសារអានបន្ថែមទៀត (ក្រៅពីសៀវភៅពុម្ព) ដើម្បីទុកសម្រាប់កុមារអាននៅផ្ទះ។

## អនុសាសន៍សម្រាប់ឪពុកម្តាយ និងអ្នកថែទាំ៖

- ត្រូវចំណាយពេលខ្លះដើម្បីអានជាមួយ និងអានឲ្យកុមារស្តាប់ទាំងមុន និងអំឡុងពេលសិក្សា។
- ត្រូវផ្តល់ប្រភេទឯកសារអានឲ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់កុមារអាននៅផ្ទះ និងធានាថាកុមារមានទីកន្លែងល្អប្រសើរសម្រាប់អាននៅផ្ទះ។
- ត្រូវចូលរួមកាន់តែសកម្មនៅក្នុងជីវិតសិក្សារបស់កុមារ រួមទាំងការចូលរួមនៅក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រង ព្រឹត្តិការណ៍ផ្សេងៗ និងកម្មវិធីដែលនឹងលើកកម្ពស់ដល់ការគ្រប់គ្រង និងអភិបាលកិច្ចសាលា ។

# ១
# សេចក្តីផ្តើម

## ១.១ អំពីកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោក

នៅក្នុងប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកធ្វើកិច្ចការដើម្បីលើកកម្ពស់ការអប់រំកុមារដែលមានអាយុពី 3-12 ឆ្នាំ តាមរយៈការអភិវឌ្ឍកុមារតូច និងអន្តរាគមន៍ប្រពលអក្ខរកម្ម ព្រមទាំងការបង្រៀនបំណិនជីវិតផងដែរ។ អង្គការទស្សនៈពិភពលោកមានគោលបំណងលើកកម្ពស់កុមារា និងកុមារីដែលមានអាយុពី 3-12 ចំនួនរាប់លាននាក់ ដោយផ្ទាល់ និងដោយប្រយោលតាមរយៈការអន្តរាគមន៍លើការសិក្សានៅចន្លោះឆ្នាំ 2017 និង 2022។ បច្ចុប្បន្ន អង្គការទស្សនៈពិភពលោក ធ្វើការនៅតាមសាលាចំនួនជិត 650 នៅក្នុងបណ្តាខេត្តទាំង 9។

កម្មវិធីរបស់អង្គការទស្សនៈពិភពលោកត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែម និងធ្វើកិច្ចការនៅក្នុងដែននៃប្រព័ន្ធអប់រំសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលបំណងនៃកម្មវិធីអប់រំគឺដើម្បីលើកកម្ពស់ និងពង្រឹងប្រព័ន្ធអប់រំជាតិដើម្បីអាចផ្តល់សេវាអប់រំគុណភាពខ្ពស់ដែលធ្វើឲ្យកុមារទទួលបានជំនាញមូលដ្ឋាននៃអក្ខរកម្ម និងលេខនពន្ធ ព្រមទាំងបំណិនជីវិតសំខាន់ៗផងដែរ។

អង្គការទស្សនៈពិភពលោកទទួលស្គាល់ថា តួអង្គជាច្រើនមានការប្តេជ្ញាចិត្តធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំ និងលើកកម្ពស់លទ្ធផលសិក្សាសម្រាប់កុមារនៅក្នុងប្រទេសកម្ពុជា ជាពិសេសរាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីសម្រេចបានលទ្ធផលទាំងនេះទាមទារឲ្យមានកិច្ចសហការ ការសម្របសម្រួល និងការប្តេជ្ញាចិត្តចំពោះគោលដៅរួមជាពិសេស **គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤** ធានាឲ្យមានការអប់រំប្រកបដោយគុណភាពដែលមានលក្ខណៈរួមបញ្ចូល និងសមភាព ព្រមទាំងលើកកម្ពស់ឱកាសសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

## ១.២ សារៈតារ និងគោលបំណងនៃការសិក្សា

ជាផ្នែកមួយនៃយុទ្ធសាស្ត្រថ្មីរបស់ខ្លួនសម្រាប់កម្មវិធីអប់រំ និងបំណិនជីវិតនៅក្នុងប្រទេសកម្ពុជា នៅក្នុងឆ្នាំ 2016 អង្គការទស្សនៈពិភពលោក (WV) បានធ្វើការវាយតម្លៃទៅលើធនធានបណ្ណាល័យនៅតាមសាលាបឋមសិក្សានៅគ្រប់ខេត្តគោលដៅរបស់ WV។ ការសិក្សានេះមានគោលបំណងវិភាគភាពអាចរកបានឯកសារអាន និងជំនួយសម្រាប់ការអានដែលកុមារទទួលបាននៅសាលា និងបង្ហាញអំពីស្ថានភាពបណ្ណាល័យនៅតាមសាលារៀន ដោយប្រៀបធៀបជាមួយស្តង់ដារជាតិសម្រាប់បណ្ណាល័យនៅតាមសាលាបឋមសិក្សា (កអយក 2011)។

ការវាយតម្លៃខាងលើបានបង្ហាញថា បណ្ណាល័យជាច្រើនមិនមានលក្ខណៈស្របតាមស្តង់ដាររបស់រដ្ឋាភិបាល ពាក់ព័ន្ធនឹងចំនួនបណ្ណារក្សដែលទទួលបានការបណ្តុះបណ្តាល (ផ្អែកលើចំនួនម៉ោងធ្វើការរបស់សាលា និងចំនួនថ្នាក់) ហើយចំនួន និងប្រភេទសៀវភៅសម្រាប់សិស្សអាននៅមានកម្រិតនៅឡើយ។ សកម្មភាពចម្បងនៅក្នុងបណ្ណាល័យគឺការអានដោយខ្លួនឯង ការនិទានរឿងល្បែងសិក្សា សកម្មភាពសិល្បៈ និងការស្រាវជ្រាវក្នុងថ្នាក់មួយចំនួន។ ទោះបីយ៉ាងណា បណ្ណាល័យទាំងអស់មិនសុទ្ធតែអនុញ្ញាតឲ្យសិស្សខ្ចីសៀវភៅឡើយ ដោយបារម្ភថាសៀវភៅដែលមានចំនួនតិចស្រាប់ទៅហើយអាចនឹងបាត់បង់ ឬខូចខាត។

ដើម្បីបំពេញបន្ថែមលើការវិភាគខាងលើ អង្គការទស្សនៈពិភពលោកបាន ធ្វើការសិក្សាបែបបរិមាណអំពីបទពិសោធន៍ និងទម្លាប់នៃការអានរបស់កុមារថ្នាក់ទី 4 និងទី 6។ ការសិក្សានេះមានគោលបំណងចំនួនបីដូចខាងក្រោម៖

1. ដើម្បីស្វែងយល់អំពីបទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងការអាននៅតាមបណ្ណាល័យសាលានិងនៅតាមផ្ទះ។
2. ដើម្បីកំណត់ភាពខុសគ្នានៅក្នុងទម្លាប់ ឬឥរិយាបថនៃការអានផ្អែកតាមភេទ
3. ដើម្បីកំណត់ថាតើមានទំនាក់ទំនងដោយផ្ទាល់រវាងភាពដែលអាចរកបាន/ការប្រើធនធាន (បណ្ណាល័យ) និងឥរិយាបថនៃការអានរបស់សិស្សដែរឬទេ។

ការសិក្សាមានគោលបំណងជួយដល់ WV ក្នុងការកែលម្អយុទ្ធសាស្ត្រដែលនឹងបង្កើនប្រសិទ្ធភាពនៃកម្មវិធីអប់រំ និងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងៗទៀតក្នុងការធ្វើសេចក្តីសម្រេចចិត្ត សម្រាប់ការផ្លាស់ប្តូរដែលនឹងជួយលើកកម្ពស់ការអប់រំកុមារគ្រប់រូបនៅក្នុងប្រទេសកម្ពុជា។

មានការយល់ស្របជាទូទៅនៅក្នុងផ្នែកអក្ខរកម្មថា  ចំនួនបទពិសោធន៍ពីការអានឯកសារមានឥទ្ធិពលខ្លាំងទៅលើការអភិវឌ្ឍអក្ខរកម្មរបស់កុមារ (Duke, 2000; Goldenberg, 2004)[1] ។ ជាងនេះទៅទៀត មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ជំនាញអក្ខរកម្មកើតមាននៅក្នុងសហគមន៍ដែលមានសកម្មភាព និងការហ្វឹកហាត់ពាក់ព័ន្ធនឹងអក្ខរកម្ម៖ "ទំនាក់ទំនងមនុស្សដូចជាការចែករំលែកសៀវភៅអមដោយរូបភាព ការនិទានរឿង និងការជជែកអំពីបទពិសោធន៍ មានសារសំខាន់ចំពោះការអភិវឌ្ឍអក្ខរកម្ម" (Wilson, 2003, p. 77)[2] ។ នេះគឺជាមូលដ្ឋានទ្រឹស្តីដែលធ្វើឲ្យ WV មានការចាប់អារម្មណ៍នៅក្នុង ការស្រាវជ្រាវអំពី (1) បរិក្ខារបណ្ណាល័យ និង (2) ទម្លាប់នៃការអានរបស់កុមារនៅក្នុង និងខាងក្រៅថ្នាក់។

ការសិក្សាផ្តោតទៅលើការយល់ឃើញរបស់សិស្សចំពោះសមត្ថភាព ទម្លាប់ និងធនធានសម្រាប់អាន។ ទោះបីជាការយល់ឃើញទាំងនេះមិនអាចធ្វើការផ្ទៀងផ្ទាត់ដោយមិនលម្អៀងក៏ដោយ ប៉ុន្តែជាការបង្ហាញអំពីស្ថានភាពជាក់ស្តែងរបស់សិស្សដូច្នេះហើយទើបវាមានសារសំខាន់។ ពុំមានការធ្វើតេស្តអក្ខរកម្មប្រកបដោយស្តង់ដារណាមួយត្រូវបានធ្វើឡើងជាផ្នែកមួយនៃការសិក្សានេះឡើយ។

---

[1] Duke, N. K. (2000). For the rich it's richer: Print experiences and environments offered to children in very low- and very high-socioeconomic status first grade classrooms. American Educational Research Journal, 37(2), 441-478. Retrieved from http://www.jstor.org/stable/1163530 and Goldenberg, C. (2004). Successful school change: Creating settings to improve teaching and learning. New York: Teachers College.
[2] Wilson, R.A. (2003). Special educational needs in the early years (2nd edition). New York, NY: Routledge Falmer.

# ២
# វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចគោលបំណងដូចដែលបានលើកឡើងខាងលើ ការសិក្សាអំពីបទពិសោធន៍ និងទម្លាប់នៃការអានត្រូវបានធ្វើឡើងដោយប្រើប្រាស់ការសិក្សាបែបបរិមាណជាចម្បង អមដោយការសួរសំណួរបើកមួយចំនួនដើម្បីជួយសម្រួលដល់ការយល់អំពី "របៀប" និង "មូលហេតុ"។ អ្នកប្រឹក្សាឯករាជ្យត្រូវបានជ្រើសរើសឲ្យបង្កើត និងគ្រប់គ្រងការប្រមូលទិន្នន័យ ព្រមទាំងវិភាគអំពីលទ្ធផលបឋមផងដែរ។

## ២.១ ការជ្រើសរើសគំរូសិក្សា

ជាសរុប អង្គការទស្សនៈពិភពលោកធ្វើការជាមួយសាលាចំនួនប្រហែល 650 នៅទូទាំង 9 ខេត្តដូចជា ខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ កណ្ដាល ព្រះវិហារ សៀមរាប និងតាកែវ។ សាលាចំនួន 40 ត្រូវបានជ្រើសរើសតាមវិធីសាស្ត្រចៃដន្យ ពីសាលាដែល WV ធ្វើការ និងមានព័ត៌មានលម្អិតស្រាប់អំពីធនធានបណ្ណាល័យ ។ សម្រាប់ការសិក្សានេះ សិស្សថ្នាក់ទី 4 ដល់ទី 6 ត្រូវបានសម្ភាសដើម្បីស្វែងយល់អំពីបទពិសោធន៍របស់ពួកគេពាក់ព័ន្ធនឹងបរិយាកាសនៃការអាននៅសាលា និងនៅផ្ទះ ព្រមទាំងទម្លាប់នៃការអានរបស់ពួកគេម្នាក់ៗផងដែរ។ សិស្សដែលជាគំរូសិក្សាមានចំនួន 507នាក់ ដែលត្រូវបានជ្រើសរើសឡើងដើម្បីផ្ដល់នូវភាពសុក្រិតចំនួនយ៉ាងតិច 5% នៅកម្រិតជឿជាក់ 95%។ ដំណើរការលម្អិតអំពីការជ្រើសរើសសាលាទាំង 40 និងសិស្សមានដូចខាងក្រោម៖

### ដំណាក់កាលទី ១៖ ការជ្រើសរើសសាលាទាំង ៤០

គោលបំណងទី 3 ព្យាយាមធ្វើការប្រៀបធៀបទម្លាប់នៃការអាន និងបរិយាកាសនៃការអានរវាងសាលា ដែលមាន និងគ្មានបណ្ណាល័យ។ ដូច្នេះ ការជ្រើសរើសគំរូសិក្សាចាត់ជាថ្នាក់ (stratified sampling) ត្រូវបានប្រើប្រាស់ដើម្បីជ្រើសរើសសាលាចំនួន40 ចេញពីសាលាចំនួន 83 [3] ដែល WV មានព័ត៌មានពេញលេញ និងគ្រប់គ្រាន់អំពីបរិក្ខារ និងធនធានបណ្ណាល័យនៅទូទាំងខេត្តគោលដៅរបស់ WV ទាំង9។ ការជ្រើសរើសត្រូវបានធ្វើឡើងតាមដំណាក់កាលដូចខាងក្រោម៖

១. ដំណាកាលទី 1៖ សាលាគោលដៅទាំង 83 នៅក្នុងខេត្តគោលដៅទាំង9 ត្រូវបានដាក់បញ្ចូលគ្នាជាបណ្ដុះគំរូសិក្សាបឋម (primary sampling unit, PSU)។

២. ដំណាក់កាលទី 2៖ សាលាទាំង 83 ត្រូវបានចាត់ថ្នាក់ទៅជាពីរថ្នាក់៖ សាលាដែលមានបណ្ណាល័យ (46 សាលា) និងសាលាដែលគ្មាន បណ្ណាល័យ (37 សាលា)។

៣. ដំណាក់កាលទី 3៖ ចេញពីថ្នាក់នីមួយៗ (stratum) វិធីសាស្ត្រប្រភាគ ( f=n/N ) ត្រូវបានប្រើប្រាស់ដើម្បីកំណត់ថាតើសាលាមកពីថ្នាក់នីមួយៗចំនួនប៉ុន្មានដែលគួរជ្រើសរើស ដើម្បីបង្កើតសាលាឲ្យបានចំនួន 40 ដែលជាចំនួនសមាមាត្រ។ ការងារនេះតម្រូវឲ្យជ្រើសរើសនូវសាលាចំនួន22 ដែលមានបណ្ណាល័យ និងសាលាចំនួន 18 ដែលគ្មានបណ្ណាល័យ ជាលទ្ធផលយើងទទួលបានគំរូសិក្សាសរុបចំនួន 40 សាលា។ ជាក់ស្ដែង សាលាមួយនឹងត្រូវបានទម្លាក់ពីគំរូសិក្សាដោយសារបញ្ហាមិនអាចទៅដល់ (សម្រាប់ព័ត៌មានបន្ថែម សូមមើលផ្នែកស្ដីពីភាពកំណត់នៃការសិក្សា)។

4. ដំណាក់កាលទី 4៖ វិធីសាស្ត្រជ្រើសរើសគំរូសិក្សាតាមវិធីសាស្ត្រចៃដន្យបែបសាមញ្ញ (simple random sampling) ត្រូវបានប្រើប្រាស់ដើម្បីចាប់យកសាលា ទាំង 22 ចេញពីសាលាដែលមានបណ្ណាល័យ ទាំង 46 និងសាលាចំនួន 18 ចេញពីសាលាដែលគ្មានបណ្ណាល័យទាំង 37។ ជាសរុបសាលាចំនួន 40 ត្រូវបានជ្រើសរើសជាសំណាក។

[3] សាលាចំនួន 83 នេះ ត្រូវបានជ្រើសរើសដោយចៃដន្យពីសាលាបឋមសិក្សាចំនួន 622 ក្នុងចំណោមសាលាទាំងអស់ក្រោមកម្មវិធីអប់រំរបស់អង្គការទស្សនៈពិភពលោក។

### ដំណាក់កាលទី ២៖ ការជ្រើសរើសសិស្សថ្នាក់ទី ៤-៦

វិធីសាស្ត្រវិសមាមាត្រ ( disproportional method ) ត្រូវបានប្រើប្រាស់ដើម្បីគណនាចំនួនសិស្សនៅតាមសាលានីមួយៗ។ ចំនួនសំណាកតម្រូវឲ្យមានសិស្សចំនួន 500 នាក់ ដែលមានន័យថាត្រូវមានសិស្សចំនួន 13នាក់ នៅតាមសាលានីមួយៗនៃសាលាទាំង 40។ សិស្សត្រូវបានជ្រើសរើស និងសម្ភាសស្មើៗគ្នាទៅតាមកម្រិតថ្នាក់ និងភេទ ( សិស្ស 4នាក់ មកពីថ្នាក់ទី 4 ដែល 2នាក់ជាសិស្សប្រុស និង 2នាក់ ជាសិស្សស្រី។ សិស្ស 4នាក់មកពីថ្នាក់ទី 5 ដែល 2នាក់ ជាសិស្សប្រុស និង 2នាក់ ជាសិស្សស្រី។ និងសិស្ស 4នាក់មកពីថ្នាក់ទី 6 ដែល 2នាក់ ជាសិស្សប្រុស និង 2នាក់ ជាសិស្សស្រី ) ហើយសិស្សទី 13 ត្រូវបានជ្រើសរើសឆ្លាស់រវាងភេទ និងកម្រិតថ្នាក់។

សិស្សចំនួន 13នាក់ ដែលមកពីសាលានីមួយត្រូវបានជ្រើសរើសពីបញ្ជីសិស្ស ( ដោយប្រើប្រាស់វិធីសាស្ត្រជ្រើសរើសគំរូសិក្សាតាមវិធីសាស្ត្រចៃដន្យសាមញ្ញ simple random sampling method ) ដោយមានការសម្របសម្រួលជាមួយនាយកសាលា និងគ្រូបង្រៀន។

## ២.២ ការបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យ

អ្នកប្រឹក្សាឯករាជ្យ និងបុគ្គលិកអង្គការទស្សនៈពិភពលោកបានបណ្តុះបណ្តាលអ្នកប្រមូលទិន្នន័យដែលមានបទពិសោធន៍ចំនួនប្រាំបីនាក់។ អ្នកប្រមូលទិន្នន័យទាំងប្រាំបីនាក់ត្រូវបានណែនាំសង្ខេបអំពីកម្មវិធី អប់រំរបស់ WV។ ជាដំបូងក្រុមទាំងមូលបានអានកម្រងសំណួរមួយសំណួរម្តងៗ ដើម្បីធានាថា យល់ច្បាស់ទាំងអំពីសំណួរ និងគោលបំណងនៃការសួរ បន្ទាប់មកបានអនុវត្តដោយសម្ភាសគ្នាទៅវិញទៅមក ហើយអ្នកប្រមូលទិន្នន័យទាំងអស់ក៏បានធ្វើការសម្ភាសសាកល្បងជាមួយកុមារម្នាក់ ដើម្បីជួយពង្រឹងជំនាញ និងធ្វើឲ្យពួកគាត់កាន់តែស្ទាត់ជំនាញជាមួយនឹងកម្រងសំណួរមុនពេលចុះអនុវត្តផ្ទាល់។ អ្នកប្រមូលទិន្នន័យនិងអ្នកប្រឹក្សាបានចុះហត្ថលេខាទទួលស្គាល់នៅលើពិធីសារឥរិយាបថការពារកុមារ និងត្រូវបានណែនាំអំពីនីតិវិធីស្រាវជ្រាវដែលមានសុវត្ថិភាព និងមានការចូលរួមពីកុមារ។

## ២.៣ ការបញ្ចូល និងការវិភាគទិន្នន័យ

អ្នកប្រមូលទិន្នន័យចំនួនបីនាក់ ដែលធ្លាប់មានបទពិសោធន៍អំពីការបញ្ចូលទិន្នន័យ បញ្ចប់ដំណើរការបញ្ចូលទិន្នន័យ។ ពួកគាត់បានទទួលការបណ្តុះបណ្តាលបន្ថែមពីអ្នកប្រឹក្សាឯករាជ្យ ពាក់ព័ន្ធនឹងការប្រើប្រាស់កម្មវិធីវិភាគទិន្នន័យហៅថា SPSS ទម្រង់នៃការបញ្ចូលទិន្នន័យ ព្រមទាំងនីតិវិធីត្រួតពិនិត្យប្រកបដោយគុណភាព។ ដើម្បីធានាសុក្រិតភាព អ្នកប្រឹក្សាឯករាជ្យបានពិនិត្យមើលឡើងវិញទៅលើកម្រងទិន្នន័យទាំងបី។ ការសម្អាតទិន្នន័យត្រូវបានធ្វើឡើងយ៉ាងម៉ត់ចត់បន្ទាប់ពីការបញ្ចូលទិន្នន័យត្រូវបានបញ្ចប់។ កំហុស ឬព័ត៌មានមិនច្បាស់លាស់ត្រូវបានផ្ទៀងផ្ទាត់ជាមួយនឹងទម្រង់ប្រមូលទិន្នន័យដើម។

ការវិភាគបែបបែបពណ៌នា ហ្វ្រេកង់ និងការប្រៀបធៀបអថេរពីរ ( descriptive statistics, frequencies and cross-tabulation ) ត្រូវបានប្រើប្រាស់សម្រាប់ការវិភាគទិន្នន័យ។ ការធ្វើតេស្តសំខាន់ៗមួយចំនួនរវាងអថេរត្រូវបានប្រើ ដោយប្រើប្រាស់ការធ្វើតេស្តស្ថិតិដូចជា Independent T-Test, Chi square និង Correlation។

សំណួរបើកទាំងអស់ត្រូវបានដាក់លេខកូដ បែងចែកប្រភេទ និងវិភាគដោយប្រុងប្រយ័ត្ន។ ការសួរសំណួរទាំងនេះបានបង្ហាញអំពីគំរូ និងនិន្នាការ ព្រមទាំងត្រូវបានស្រង់ជាទិន្នន័យបរិមាណសម្រាប់ធ្វើការវិភាគ។

**សម្គាល់៖** ក្រាហ្វិកមួយចំនួនដែលបានបង្ហាញនៅក្នុងរបាយការណ៍ ភាគរយ (%) សរុបនឹងមានចំនួនលើសពី 100% ដោយសារសំណួរមួយចំនួនត្រូវបានសួរ និងផ្តល់នូវពហុជម្រើសដែលមានចម្លើយច្រើន។ ក្រាហ្វិកត្រូវបានបង្ហាញជាលទ្ធផលសំខាន់ទាំងជាភាគរយករណី ឬភាគរយចម្លើយ។ [4]

## ២.៣ ភាពកំណត់របស់ការសិក្សា

មានបញ្ហាប្រឈមសំខាន់ចំនួនបីនៅក្នុងការសិក្សានេះ៖

- នៅតាមសាលាមួយចំនួនតូច មានការលំបាកក្នុងការអនុវត្តឲ្យបានដូចៗគ្នានូវវិធីសាស្ត្រជ្រើសរើសសិស្សដើម្បីសម្ភាសដោយសារតែប្រព័ន្ធប្តូរវេនសិក្សាចុះឡើងនៅតាមសាលាបឋមសិក្សាកម្ពុជា។ ឧទាហរណ៍សិស្សមករៀនតែនៅពេលព្រឹក ចំណែកនៅសាលាផ្សេងទៀត សិស្សរៀនទាំងវេនព្រឹក និងវេនល្ងាច។ អ្នកប្រមូលទិន្នន័យចុះតាមសាលាតែម្តងប៉ុណ្ណោះ ហើយសិស្សមួយចំនួនដែលបានជ្រើសរើសរួចពីដំណើរការជ្រើសរើសគំរូសិក្សាដោយចៃដន្យមិនមានវត្តមាន។ នៅក្នុងករណីទាំងនេះ សិស្សផ្សេងទៀតត្រូវបានជ្រើសរើសតាមវិធីសាស្ត្រចៃដន្យពីសិស្សដែលមានវត្តមាននៅកំឡុងពេលប្រមូលទិន្នន័យ។
- ចម្ងាយពីសាលាមួយទៅសាលាមួយទៀត និងរដូវវស្សាបង្កឲ្យមានការលំបាកក្នុងការធ្វើដំណើរនៅតាមតំបន់ជនបទ សាលាមួយក្នុងចំណោមសាលាចំនួន 40 ដែលបានជ្រើសរើសពីដំបូងមិនអាចធ្វើដំណើរទៅដល់ ដូច្នេះមានសាលាចំនួនតែ 39 ប៉ុណ្ណោះដែលត្រូវបានសិក្សា។
- ក្នុងចំណោមសាលាទាំង 39 មានសាលាចំនួន 7 គឺជាសាលាដែលគ្មានបណ្ណាល័យ។ ចំនួននេះខុសពីផែនការដំបូងដែលត្រូវពិនិត្យមើលសាលាចំនួន18 ដែលគ្មានបណ្ណាល័យ ដើម្បីប្រៀបធៀបសាលាទាំងពីរប្រភេទ។ ជាលទ្ធផល សាលាចំនួន 7 ដែលមានបណ្ណាល័យត្រូវបានជ្រើសរើសដោយចៃដន្យដើម្បីប្រៀបធៀបជាមួយសាលាចំនួន 7 ដែលគ្មានបណ្ណាល័យ (ដែលអាចដាក់កំហិតទៅលើភាពរឹងមាំនៃការសិក្សានៅក្នុងការឆ្លើយតបគោលបំណងទី 3)។

---

[4] ភាគរយចម្លើយគឺជាភាគរយសរុបទាំងអស់។ ភាគរយករណីគឺជាភាគរយសម្រាប់ធាតុនីមួយៗ (សម្រាប់សំណួរពហុចម្លើយ)។

# វិសាលភាពនៃការសិក្សា

9 ខេត្ត 27 ស្រុក និង 39 សាលា



# ៣
# លទ្ធផលនៃការសិក្សា

លទ្ធផលនៃការសិក្សាមានបង្ហាញក្រោមចំណងជើងសំខាន់ចំនួនបួន៖ (1) កម្រងទិន្នន័យប្រជាសាស្ត្ររបស់សិស្ស (2) បទពិសោធន៍អាននៅផ្ទះរបស់សិស្ស (3) នៅសាលា និង (4) ទម្លាប់នៃការអានរបស់សិស្ស។

## ៣.១ ព័ត៌មានប្រជាសាស្ត្ររបស់សិស្សដែលបានសិក្សា

ជាសរុបអង្គការទស្សនៈពិភពលោក បានសិក្សាទៅលើសិស្សចំនួន 507 នាក់នៅតាមសាលាចំនួន 39 នៅទូទាំង 27 ស្រុក នៅក្នុងខេត្តទាំង 9 គឺខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ កំពង់ស្ពឺ កណ្ដាល ព្រះវិហារ សៀមរាប និងតាកែវ។ នៅក្នុងចំណោមសិស្សដែលបានស្ទង់មតិ មានស្រីចំនួន 51% (ស្មើនឹង 261នាក់) និងប្រុសចំនួន 49% (ស្មើនឹង 246នាក់)។

ក្នុងចំណោមសិស្សចំនួន 507នាក់ មាន 170នាក់ មកពីថ្នាក់ទី 4, 176នាក់ មកពីថ្នាក់ទី 5 និង 161នាក់មកពីថ្នាក់ទី 6។ របាយអាយុនៃសិស្ស មានពី 8 ដល់ 16ឆ្នាំ ដោយមានអាយុជាមធ្យម 12ឆ្នាំ។ សិស្សជាច្រើនដែលត្រូវបានសម្ភាសមានអាយុច្រើនជាងអាយុស្តង់ដារបើប្រៀបធៀបទៅនឹងកម្រិតថ្នាក់ដែលពួកគេកំពុងសិក្សា។ បញ្ហាគឺដោយសារតែសិស្សមានការយឺតយ៉ាវក្នុងការចុះឈ្មោះចូលរៀន ឬបានរៀនត្រួតថ្នាក់។

*តារាងទី ១៖ ចំនួនសិស្សសំណាកតាម ភេទ និងថ្នាក់*

| កម្រិតថ្នាក់បច្ចុប្បន្នរបស់សិស្ស | | | | | |
|---|---|---|---|---|---|
| | | ថ្នាក់ទី ៤ | ថ្នាក់ទី ៥ | ថ្នាក់ទី ៦ | សរុប / ភេទ |
| ភេទ | ប្រុស | 82 (16.2%) | 87 (17.2%) | 77 (15.2%) | 246 (48.5%) |
| | ស្រី | 88 (17.4%) | 89 (17.6%) | 84 (16.6%) | 261 (51.5%) |
| សរុបថ្នាក់ | | 170 (33.5%) | 176 (34.7%) | 161 (31.8%) | 507 (100%) |

តារាងទី ២៖ ចំនួនសិស្សសំណាកតាម អាយុ

| អាយុរបស់សិស្ស | |
|---|---|
| ទាបបំផុត | 8 |
| ខ្ពស់បំផុត | 16 |
| មធ្យម | 12 |

## ៣.២ បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសអាននៅផ្ទះ

កត្តាសំខាន់មួយដែលប៉ះពាល់ទៅដល់ទម្លាប់អានរបស់សិស្សគឺគ្រួសាររបស់សិស្ស និងបរិយាកាសអាននៅតាមផ្ទះ។ ផ្នែកនេះពណ៌នាអំពីបទពិសោធន៍អាននៅផ្ទះរបស់សិស្ស និងកត្តាដែលប៉ះពាល់ទៅដល់បរិយាកាសអាននៅផ្ទះដែលអាចជះឥទ្ធិពលទៅលើសកម្មភាពអាន និងការយល់ឃើញ អំពីសមត្ថភាព អានផ្ទាល់ខ្លួន។

### ៣.២.១ ការយល់ឃើញអំពីសមត្ថភាពអាន

ក្នុងចំណោមសិស្សដែលបានធ្វើការស្ទង់មតិទាំងអស់ មានសិស្សចំនួន 13.6% បានធ្វើចំណាត់ថ្នាក់សមត្ថភាពអាន របស់ខ្លួនថា "ល្អណាស់" 36.1% ថា "ល្អបង្គួរ" និង15% ថា "ល្អ"។ មានសិស្សចំនួនតែ 24.9% ប៉ុណ្ណោះដែលបាននិយាយថាមានកម្រិតមធ្យម 8% ថា "ខ្សោយ" និង 2% ថា "ខ្សោយណាស់"។ ដោយសារសិស្សដែលបានស្ទង់មតិស្ថិតនៅកម្រិតថ្នាក់ខុសៗគ្នា (4 ទៅ 6) ការយល់ឃើញលើភាពស្ទាត់ជំនាញក្នុងការអានជាក់ស្តែងរបស់សិស្សអានមានលក្ខណៈខុសគ្នា ទៅតាមកម្រិតថ្នាក់នីមួយៗ និងពីសិស្សម្នាក់ទៅសិស្សម្នាក់។

ដូច្នេះ ការធ្វើតេស្តស្ថិតិត្រូវបានប្រើប្រាស់ដើម្បីកំណត់ភាពខុសគ្នារវាងការយល់ឃើញរបស់សិស្សចំពោះភាពស្ទាត់ជំនាញក្នុងការអាន និងកម្រិតថ្នាក់។ ការធ្វើតេស្តបានយល់ស្របនឹងសម្មតិកម្ម និងបានបង្ហាញអំពីភាពខុសគ្នាថាមានកម្រិតខ្ពស់ $p<.05$ ដែលមានន័យថាសិស្សដែលរៀនថ្នាក់កាន់តែខ្ពស់ទំនងជារៀបរាប់អំពីការយល់ឃើញកាន់តែប្រសើរចំពោះភាពស្ទាត់ជំនាញក្នុងការអាន ចំណែកសិស្សរៀនថ្នាក់កាន់តែទាបទំនងយល់ឃើញថា ភាពស្ទាត់ជំនាញក្នុងការអាន កាន់តែទាបដែរ។

*ក្រាហ្វ 1៖ ការយល់ឃើញរបស់សិស្សចំពោះភាពស្ទាត់ជំនាញក្នុងការអានទតាមកម្រិតថ្នាក់*



## ៣.២.២ បរិយាកាសអក្ខរកម្មនៅតាមផ្ទះ

ការសិក្សាបានបង្ហាញអំពីតួនាទីដ៏សំខាន់របស់សមាជិកគ្រួសារនៅក្នុងការជួយសិស្សឲ្យចេះ អាន និងសរសេរតាំងពីកុមារភាព។ ខណៈដែលការសិក្សាបានបង្ហាញថា គ្រូជាបុគ្គលសំខាន់បំផុតនៅក្នុងការជួយសិស្សឲ្យចេះអានអក្សរ (ដោយសិស្ស72%) ម្ដាយ (66%) និងឪពុក (61%) ជាបុគ្គលសំខាន់បន្ទាប់។ សិស្សក្នុងចំនួនភាគរយខ្ពស់ក៏បាននិយាយផងដែរថា បងស្រី (28.2%) បងប្រុស (19.7%) ឬមិត្តភក្តិ (21.1%) របស់ខ្លួនមានតួនាទីសំខាន់នៅក្នុងការជួយខ្លួនរៀនអានអក្សរដែរ។

*ក្រាហ្វ 2៖ បុគ្គលសំខាន់បំផុតចំនួនបីដែលជួយកុមារឲ្យរៀនចេះអាន និង សរសេរកាលពីនៅកុមារភាព*




សិស្សដែលបានស្ទង់មតិបាននិយាយអំពីបរិយាកាសអានវិជ្ជមាននៅតាមផ្ទះ និងបាននិយាយថា សមាជិកគ្រួសារបានចូលរួមការអានជាមួយពួកគេ។ សិស្សស្ទើរតែទាំងអស់ (94%) បាននិយាយថាសមាជិកគ្រួសារ "តែងតែលើកទឹកចិត្ត" ឬបានជួយខ្លួនក្នុងការអាននៅពេលដែលខ្លួននៅវ័យកុមារភាព។ សិស្សតិចជាងនេះបន្តិច (74.4%) បាននិយាយថា សមាជិកគ្រួសារ "តែងតែអានរឿង ឬសៀវភៅ" ឲ្យខ្លួនស្ដាប់នៅពេលខ្លួននៅវ័យកុមារភាព។

*ក្រាហ្វ 3៖ បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងការអាននៅផ្ទះកាលនៅពីតូច*



នៅពេលត្រូវបានសាកសួរអំពីបទពិសោធន៍ក្នុងការអាននៅផ្ទះនាពេលថ្មីៗនេះ ( កាលពីសប្តាហ៍មុន ) សិស្សបានបង្ហាញថាបទពិសោធន៍មានទំនោរផ្សេងៗ។ កាលពីសប្តាហ៍កន្លងទៅ មានសិស្សចំនួន 63.4% បានបញ្ជាក់ថាបានឃើញអ្នកផ្ទះខ្លួនអានអក្សរ។ ភាគរយបានធ្លាក់ចុះនៅពេលត្រូវបានសួរអំពីការចូលរួមសកម្មជាងនេះរបស់សមាជិកគ្រួសារ ពោលគឺ 59.2% ក្នុងចំណោមសិស្សទាំងអស់បានរៀបរាប់ថា សមាជិកគ្រួសារម្នាក់បានជួយខ្លួនក្នុងការធ្វើកិច្ចការផ្ទះ 56.5% មានសមាជិកគ្រួសារអានឲ្យខ្លួនស្តាប់ ហើយមានតែ 50% ប៉ុណ្ណោះដែលបានអានសៀវភៅរឿងព្វេៗឲ្យខ្លួនស្តាប់។

*ក្រាហ្វ 4៖ បទពិសោធន៍បច្ចុប្បន្នរបស់សិស្សពាក់ព័ន្ធនឹងការអាននៅផ្ទះ*




## ៣.២.៣ ឯកសារអានដែលមាននៅផ្ទះ

បើនិយាយអំពីភាពដែលអាចរកបាន និងភាពសម្បូរបែបនៃធនធានអាននៅផ្ទះវិញ សិស្សបានរៀបរាប់ថា សៀវភៅពុម្ពគឺជាឯកសារអានដែលតែងតែមាននៅផ្ទះ។ សិស្សស្ទើរតែទាំងអស់បានរៀបរាប់ថាមានសៀវភៅពុម្ពមួយក្បាល បន្ទាប់មកគឺសៀវភៅរឿង និងសៀវភៅសាសនា។

ក្រាហ្វិកខាងក្រោមបង្ហាញថា សិស្សចំនួន 97.6% ក្នុងចំណោមសិស្សទាំង 507នាក់ បានរៀបរាប់ថាមានសៀវភៅពុម្ពយ៉ាងតិចមួយក្បាលនៅផ្ទះ ចំណែក 53.6% បានរៀបរាប់ថាមានសៀវភៅរឿង និង 36%មានសៀវភៅសាសនា។ មានសិស្សមិនច្រើនទេដែលបានរៀបរាប់ថាមានឯកសារអានប្រភេទផ្សេងៗទៀតនៅផ្ទះ ដូចដែលបានបង្ហាញនៅក្នុងក្រាហ្វ 5។

*ក្រាហ្វ 5៖ ភាគរយសិស្សដែលមានឯកសារអានផ្សេងៗនៅផ្ទះ*




## ៣.២.៤ សំណូមពរសម្រាប់គ្រួសារក្នុងការជួយសិស្សឲ្យអានបានកាន់តែស្ទាត់ជំនាញ

បើតាមការយល់ឃើញរបស់សិស្ស គ្រួសារពិតជាមានតួនាទីសំខាន់ក្នុងការជួយអភិវឌ្ឍជំនាញអានរបស់សិស្ស។ តាមរយៈសំណួរបើក សិស្សបានសំណូមពរវិធីសាស្ត្រផ្សេងៗដែលសមាជិកគ្រួសាររបស់ខ្លួនអាចជួយខ្លួនក្នុងការអានបានកាន់តែប្រសើរ។ សំណូមពរភាគច្រើនបំផុតគឺសូមឲ្យគ្រួសារផ្តល់ការគាំទ្រ ការយកចិត្តទុកដាក់ និងចំណាយពេលទៀងទាត់ដើម្បីបង្រៀនខ្លួនអំពីការ អានអក្សរ ដោយអានឲ្យឮៗ ដើម្បីខ្លួនអាចអានតាម។ សិស្សចង់ឲ្យគ្រួសារលើកទឹកចិត្តខ្លួន ជាពិសេសនៅក្នុងការសិក្សារបស់ខ្លួន និងជួយខ្លួនលើការបញ្ចេញសំឡេង ឬប្រកបពាក្យពិបាកៗ។

សិស្សមួយចំនួនបានរៀបរាប់ថា ខ្លួនត្រូវការឲ្យគ្រួសារទុកពេលឲ្យខ្លួនរៀនសូត្របន្ថែមទៀតជាជាងតម្រូវឲ្យខ្លួនធ្វើការងារផ្សេងៗទៀត (ចំណុចនេះមិនត្រូវបានបញ្ជាក់លម្អិតឡើយ ប៉ុន្តែអាចសំដៅលើកិច្ចការផ្ទះផ្សេងៗដូចជា ការចម្អិនអាហារ មើលប្អូន និងការងារក្នុងគ្រួសារផ្សេងៗទៀត) និងជួយសម្រួលឲ្យខ្លួនបានមករៀនទៀងទាត់។ ក្រៅពីនេះ សិស្សបានបង្ហាញថា ខ្លួនចង់បានជំនួយពីគ្រួសារដើម្បីតាមដានការសិក្សារបស់ខ្លួន និងប្រើប្រាស់វិធីសាស្ត្រអហិង្សាជាមួយខ្លួន និងទិញសៀវភៅឲ្យខ្លួនអាន។ ការស្រាវជ្រាវបន្ថែមទៅលើមូលហេតុទាំងនេះ រួមមានឧទាហរណ៍កាន់តែច្បាស់លាស់អំពីវិធីសាស្ត្រពាក់ព័ន្ធផ្សេងទៀត (ដូចជា “វិធីមិនប្រើហិង្សា”) នៅមិនទាន់មានច្រើននៅឡើយទេ។

## ៣.៣ បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសអាននៅតាមសាលា

ផ្នែកនេះរៀបរាប់ពីបរិយាកាសអានក្នុងថ្នាក់ ការចេញចូល និងការប្រើប្រាស់បណ្ណាល័យ និងសំណូមពរដើម្បីលើកទឹកចិត្តឲ្យមានការប្រើប្រាស់បណ្ណាល័យបន្ថែមទៀត។

## ៣.៣.១ ការគាំទ្រការអានរបស់សិស្សនៅតាមថ្នាក់រៀន និងដោយគ្រូបង្រៀន

ចំនួនសិស្សដែលបាននិយាយថា ខ្លួនពេញចិត្តចំពោះការគាំទ្ររបស់គ្រូមានកម្រិតខ្ពស់៖ សិស្សចំនួន 93% បាននិយាយថា គ្រូរបស់ខ្លួនបានបង្រៀនខ្លួនអំពីសំឡេងអក្សរ និងពាក្យផ្សេងៗ ហើយចំនួន 68.8% បាននិយាយថា គ្រូរបស់ខ្លួនបានអានសៀវភៅផ្សេងក្រៅពីសៀវភៅពុម្ពពួៗឲ្យខ្លួនស្តាប់។ បើគិតអំពីប្រភេទសកម្មភាពទាំងនេះ មានសិស្សចំនួន 77% បានយល់ឃើញថា ការគាំទ្ររបស់គ្រូ "មានប្រយោជន៍ខ្លាំង" ចំណែក 22.7% យល់ឃើញថា "មានប្រយោជន៍ដែរ" និងមានតែ 0.3% ប៉ុណ្ណោះដែលគិតថា "មិនមាន ប្រយោជន៍ទាល់តែសោះ"។ ក្រៅពីនេះ មានសិស្សចំនួន 92.7% បានរៀបរាប់ថា គ្រូបានសួរខ្លួនអំពីឯកសារដែលខ្លួនកំពុងអាន[5] និងចំនួន 83.3% បានរៀបរាប់ថា ខ្លួនបានរៀនអំពីចម្រៀង និងល្បែងមួយចំនួននៅក្នុងថ្នាក់។

សិស្សស្ទើរតែទាំងអស់ដែលបានស្ទង់មតិ (97.2%) បានរៀបរាប់ថា នៅសាលា ខ្លួនអាន ជាមួយមិត្តរួមថ្នាក់។ សិស្សចំនួន 87% បានរៀបរាប់ថា ខ្លួនអាចអានអក្សរខ្សឹបៗដោយខ្លួនឯងដោយពុំចាំបាច់ត្រូវការជំនួយឡើយ ។[6]

## ៣.៣.២ ការចូលអានសៀវភៅនៅក្នុងបណ្ណាល័យ

ពាក់ព័ន្ធនឹងការចូលអានសៀវភៅក្នុងបណ្ណាល័យសាលា ការសិក្សានេះបានបង្ហាញថា សិស្សចំនួន 433នាក់ (85%) មកពីសាលាចំនួន 32 មានបណ្ណាល័យ[7] នៅក្នុងសាលារបស់ខ្លួន ចំណែកសិស្សចំនួន 15% មកពីសាលាចំនួន 7 ផ្សេងទៀតបានរៀបរាប់ថាពុំមានបណ្ណាល័យនៅក្នុងសាលារបស់ខ្លួនឡើយ។ ក្នុងចំណោមសិស្សដែលបាននិយាយថាមានបណ្ណាល័យនៅក្នុងសាលា ភាគច្រើន (73%) បាននិយាយថា បណ្ណាល័យបើកចំនួន 5-6 ថ្ងៃក្នុងមួយសប្តាហ៍ ប៉ុន្តែភាគរយបានថយចុះយ៉ាងរហ័សទៅតាមចំនួនថ្ងៃបណ្ណាល័យបើកតិចជាងនេះ។

*ក្រាហ្វ 6៖ ចំនួនថ្ងៃដែលបណ្ណាល័យបើកក្នុងមួយសប្តាហ៍ដែលសិស្សបានរៀបរាប់*




5 សំណួរនេះស្របទៅនឹងការអនុវត្តការបង្រៀនដើម្បីបង្កើនចំណេះដឹងនៃការអាន ប៉ុន្តែព័ត៌មានលម្អិតអំពីប្រភេទឯកសារ និងទីកន្លែងដែលសិស្សអានពុំមានបញ្ជាក់ឡើយ។

6 នេះហាក់ដូចជាកម្រិតខ្ពស់នៃទំនុកចិត្តលើការអានជាលក្ខណៈបុគ្គល បើធៀបនឹងការស្ទាបស្ទង់លើសមត្ថភាពអក្ខរកម្មជាក់ស្តែង (ដូចជាអត្រាកុមារប្រឡងជាប់មុខវិជ្ជាខ្មែរ ដែលបានបង្ហាញនៅក្នុងរបាយការណ៍សន្និបាទអប់រំ យុវជននិងកីឡារបស់ កអយក ឆ្នាំ 2016)

7 មានស្ថានភាពបណ្ណាល័យខុសៗគ្នាចំនួនប្រាំ នៅក្នុងគោលនយោបាយស្តីពី ស្តង់ដារបណ្ណាល័យបឋមសិក្សារបស់ កអយក (2011)

បណ្ណាល័យត្រូវបានបញ្ជាក់ថា បើកញឹកញាប់ដែរ (សិស្សចំនួន90% បានរៀបរាប់ថា យ៉ាងតិចបើក3 ថ្ងៃក្នុងមួយសប្តាហ៍)។ ទោះបីជាយ៉ាងណា បើនិយាយអំពីចំនួនម៉ោងបើកក្នុងមួយថ្ងៃ សិស្សបានបង្ហាញអំពីភាពខុសគ្នាខ្លាំង៖ 23.1% បាននិយាយថាបណ្ណាល័យបើកចំនួន 8 ម៉ោង 1.2% បាននិយាយថា 7 ម៉ោង 1.6% បាននិយាយថា 6 ម៉ោង 4.4% បាននិយាយថា 5 ម៉ោង 16.9% បាននិយាយថា 4 ម៉ោង 11.1% បានបញ្ជាក់ថា 3 ម៉ោង 10.6% បាននិយាយថា 2 ម៉ោង 12.7% បាននិយាយថា 1 ម៉ោង និង 3.2% បាននិយាយថាតិចជាង 30 នាទី។ ការយល់ដឹងរបស់សិស្សអាចនៅមានកម្រិតលើចំនុចនេះ ដោយផ្អែកទៅលើថាតើពួកគេទៅរៀននៅវេនព្រឹក ឬវេនរសៀល (បញ្ហានេះត្រូវបានទទួលស្គាល់នៅក្នុងផ្នែកភាពកំណត់នៃការសិក្សា)។

លទ្ធផលទាំងនេះបង្ហាញថា បណ្ណាល័យជាច្រើនមិនបានដំណើរការទៀងទាត់ទៅតាមម៉ោងបង្រៀនរបស់សាលាដូចដែលបានកំណត់ដោយ កអយក (2011) ស្តីពីស្តង់ដារបណ្ណាល័យបឋមសិក្សាឡើយ។ លទ្ធផលនេះគឺដូចគ្នាទៅនឹងការរកឃើញមុនៗរបស់អង្គការទស្សនៈពិភពលោកដែរ។

ក្រាហ្វ 7 បង្ហាញអំពីដំណើរការនៃបណ្ណាល័យ ដោយប្រៀបធៀបទៅនឹងចំនួនថ្ងៃក្នុងមួយសប្តាហ៍ និងចំនួនម៉ោងក្នុងមួយថ្ងៃ ដែលត្រូវបានសិស្សបញ្ជាក់ថា បានបើកដំណើរការ។ ការធ្វើតេស្តស្ថិតិត្រូវបានធ្វើឡើងដើម្បីកំណត់ភាពជាប់ពាក់ព័ន្ធខាងលើ។ លទ្ធផលធ្វើតេស្តបានបង្ហាញថាមានការពាក់ព័ន្ធគ្នាយ៉ាងខ្លាំងក្នុងកម្រិត $p<.05$ រវាងចំនួនថ្ងៃ និងរយៈពេលដែលបណ្ណាល័យបើកក្នុងមួយថ្ងៃ ឬអាចនិយាយបានថា បណ្ណាល័យដែលបើកចំនួនតែ 1, 2 ឬ 3 ថ្ងៃក្នុងមួយសប្តាហ៍ក៏ទំនងជានឹងបើកចំនួនតិចម៉ោងក្នុងមួយថ្ងៃផងដែរ។

*ក្រាហ្វ 7៖ ចំនួនថ្ងៃក្នុងមួយសប្តាហ៍ និងចំនួនម៉ោងក្នុងមួយថ្ងៃដែលបណ្ណាល័យត្រូវបានបើក ដែលសិស្សបានបញ្ជាក់*



## ៣.៣.៣ ការចូលអាន ការប្រើប្រាស់ និងកម្រិតពេញចិត្តរបស់សិស្សចំពោះបណ្ណាល័យសាលាពេលបច្ចុប្បន្ន

ភាពញឹកញាប់នៃការប្រើប្រាស់បណ្ណាល័យរបស់សិស្សនៅក្នុងសប្តាហ៍កន្លងទៅ មានភាពខុសគ្នាខ្លាំង។ សិស្សយ៉ាងតិចចំនួន 16% នៅសាលាដែលមានបណ្ណាល័យមិនបានប្រើប្រាស់បណ្ណាល័យក្នុងសប្តាហ៍កន្លងទៅឡើយ។ សិស្សផ្សេងទៀតមានរបាយនៃការប្រើប្រាស់បណ្ណាល័យមិនដូចគ្នាឡើយរវាង ‘1 ដង’ ឬ ‘ច្រើនជាង 4’ ដង។

សម្មិតកម្មមូលហេតុដែលពួកគេមិនបានប្រើប្រាស់បណ្ណាល័យ ឬប្រើប្រាស់តែម្តង គឺអាចរាប់បញ្ចូលបញ្ហាបណ្ណាល័យដែលពុំមានឯកសារអានសម្បូរបែប និង/ឬពុំមានបណ្ណារក្សដែលមានជំនាញដើម្បីលើកទឹកចិត្តសិស្សឲ្យប្រើប្រាស់បណ្ណាល័យ។

ការសិក្សាទៅលើបណ្ណាល័យពីមុនៗរបស់ WV [មិនបានផ្សព្វផ្សាយ] បានរកឃើញថា ចំនួន 60% នៃសាលាចំនួន 83 ពុំមានបណ្ណារក្សគ្រប់គ្រាន់ (រួមទាំងសាលាមួយចំនួនដែលគ្មានបណ្ណារក្សផង) បើធៀបទៅនឹងម៉ោងធ្វើការរបស់សាលា។

*ក្រាហ្វ ៨៖ ភាពញឹកញាប់នៃការប្រើប្រាស់បណ្ណាល័យរបស់សិស្សក្នុងសប្តាហ៍កន្លងទៅ*




លទ្ធផលវិជ្ជមានពីការប្រើប្រាស់បណ្ណាល័យហាក់មានភាពផ្ទុយគ្នាទៅនឹងរយៈពេលដែលសិស្សចំណាយនៅក្នុងបណ្ណាល័យក្នុងមួយពេលៗ។ រយៈពេលដែលបានបញ្ជាក់ញឹកញាប់បំផុត គឺតិចជាង 5 នាទី (27.5%) បន្ទាប់មកគឺ 6-10 នាទី (22.7%), 11-20 នាទី (20.2%) និង 21-30 នាទី (20%)។ មានសិស្សដែលបានស្ទង់មតិចំនួនតែ 1.9% ប៉ុណ្ណោះដែលបានចំណាយពេលនៅក្នុងបណ្ណាល័យច្រើនជាងមួយម៉ោងក្នុងមួយពេល។

*ក្រាហ្វ ៩៖ រយៈពេលប្រើប្រាស់បណ្ណាល័យដែលបានរៀបរាប់របស់សិស្សក្នុងមួយពេល*




អត្រាសិស្សខ្ចីសៀវភៅពីបណ្ណាល័យក៏មានកម្រិតទាបខ្លាំង។ មានសិស្សតែចំនួន 54.8% ប៉ុណ្ណោះដែលបានបញ្ជាក់ថា ធ្លាប់បានខ្ចីសៀវភៅពីបណ្ណាល័យ ចំណែក 45.2% ទៀតមិនធ្លាប់ ខ្ចីឯកសារណាមួយឡើយ។ មូលហេតុភាគច្រើនបំផុតដែលធ្វើឲ្យសិស្សមិនសូវខ្ចីសៀវភៅគឺ សិស្សមានការព្រួយបារម្ភខ្លាំងអំពីការបាត់បង់ ឬខូចខាតសៀវភៅនៅពេលខ្លួនយកសៀវភៅមកផ្ទះ។ សិស្សផ្សេងទៀតបានបង្ហាញចម្លើយផ្សេងៗ ដូចជាពួកគេខ្លាចគ្រូដាក់ពិន័យ ឬស្តីបន្ទោសប្រសិនបើខ្លួនធ្វើឲ្យខូចខាត ឬបាត់បង់សៀវភៅ ដូច្នេះសិស្សមិនហ៊ានខ្ចីឡើយ។ សិស្សមួយចំនួនក៏បានរៀបរាប់ផងដែរថា គ្រូមិនបានអនុញ្ញាតឲ្យខ្លួនខ្ចីសៀវភៅឡើយ ដោយសារនៅក្នុងបណ្ណាល័យពុំមានសៀវភៅច្រើនឡើយ ហើយវាអាចធ្វើឲ្យខ្វះសៀវភៅសម្រាប់សិស្សផ្សេងទៀតអាន។ ការសន្ទនាជាមួយបណ្ណារក្សកន្លងមករបស់អង្គការទស្សនៈពិភពលោកបានបង្ហាញច្បាស់អំពីការពិតមួយថា សិស្សមិនសូវចូលបណ្ណាល័យញឹកញាប់ដោយសារតែពុំមានសៀវភៅថ្មី។

នៅពេលធ្វើការវាស់វែងអំពីការពេញចិត្តចំពោះបណ្ណាល័យ សូចនាករនេះបានទទួលអត្រាមិនពេញចិត្តខ្ពស់បំផុតក្នុងចំណោមសេវាដែលបានវាស់វែង ដោយមានសិស្សប្រហែល 25% បាននិយាយថា “មិនសូវពេញចិត្ត” លើសេវាខ្ចីសៀវភៅ។

នៅពេលឆ្លុះបញ្ចាំងទៅលើបទពិសោធន៍របស់សិស្សអំពីការប្រើប្រាស់បណ្ណាល័យសាលា សិស្សបាននិយាយថា ជាទូទៅបណ្ណាល័យពុំមានប្រភេទឯកសារអានដែលខ្លួនស្វែងរកឡើយ។ មានសិស្សចំនួនតែ 32% ប៉ុណ្ណោះដែលបាននិយាយថាខ្លួនតែងតែអាចរកបានប្រភេទឯកសារដែលខ្លួនកំពុងស្វែងរក រីឯចំនួន 54.2% បានបញ្ជាក់ថាពេលខ្លះរកបាន និងចំនួន 13.8% យល់ថា កម្រ ឬមិនដែលមានទាល់តែសោះ។ ទោះបីយ៉ាងណា ពិន្ទុទូទៅចំពោះបណ្ណាល័យសាលាគឺល្អ។

*ក្រាហ្វ 10៖ ការពេញចិត្តរបស់សិស្សចំពោះបទពិសោធន៍ប្រើប្រាស់បណ្ណាល័យ*




## ៣.៣.៤ សំណូមពររបស់សិស្សក្នុងការលើកកម្ពស់ការប្រើប្រាស់បណ្ណាល័យ

សំណួរបើកបានជួយសម្រួលដល់សំណូមពររបស់សិស្សសម្រាប់ការបង្កើនការប្រើប្រាស់បណ្ណាល័យ។

សំណូមពរភាគច្រើនបំផុតគឺចង់ឃើញបណ្ណាល័យមានសៀវភៅច្រើនជាងមុន និងមានច្រើនប្រភេទ ដូចជាសៀវភៅពុម្ពគ្រប់មុខវិជ្ជា សៀវភៅរឿងថ្មីៗ សៀវភៅដែលមានពាក្យសំណេរច្រើនជាងមុន សៀវភៅពាក់ព័ន្ធនឹងកសិកម្ម និងសុខភាព សៀវភៅសាសនា សៀវភៅភាសាអង់គ្លេស វចនានុក្រម និងសៀវភៅផ្សេងៗទៀតដែលសិស្សអាចប្រើប្រាស់ជាឯកសារយោងដើម្បីធ្វើកិច្ចការសាលា ជាដើម។

សំណូមពរភាគច្រើនផ្សេងៗទៀតពាក់ព័ន្ធនឹងអគារ និងបរិក្ខារបណ្ណាល័យ ដូចជាគួរមានអគារ ឬបន្ទប់ដាច់ដោយឡែក សម្រាប់បណ្ណាល័យ (បណ្ណាល័យដាច់តែឯង) ជាជាងការដាក់ចូលគ្នាជាមួយបន្ទប់រៀន ឬទីចាត់ការ។ ការសង្កេតពីមុនៗរបស់អង្គការទស្សនៈពិភពលោកចំពោះបណ្ណាល័យបានបង្ហាញថា បណ្ណាល័យចំនួន 23% (ក្នុងចំណោម 83 ដែលបានសិក្សា) គឺជាបណ្ណាល័យចល័ត ឬបណ្ណាល័យដែលស្ថិតនៅកាច់ជ្រុងទីចាត់ការ ឬកាច់ជ្រុងថ្នាក់រៀន។ សំណូមពរផ្សេងៗទៀតសម្រាប់ការកែលម្អគឺពាក់ព័ន្ធនឹងបញ្ហាសណ្តាប់ធ្នាប់ និងអនាម័យ។ សិស្សមួយចំនួនបានសំណូមពរថា បណ្ណាល័យគួរមានការរៀបចំល្អប្រសើរជាងមុន ហើយសិស្សមួយចំនួនផ្សេងទៀតបានសំណូមឲ្យមានការគោរពចំពោះវិន័យបណ្ណាល័យ (ដូចជា រក្សាភាពស្ងៀមស្ងាត់នៅពេលអានសៀវភៅជាដើម)។ ជាចុងក្រោយ សិស្សក៏បានសំណូមពរចំពោះបណ្ណារក្សផងដែរថា៖ បណ្ណារក្សគួរមានអាកប្បកិរិយាល្អ (រស់រាយ ចិត្តល្អ និងបង្ហាញការស្វាគមន៍) ហើយគួរអានសៀវភៅរឿងឲ្យសិស្សស្តាប់ឲ្យបានញឹកញាប់ជាងមុន។

# ៣.៤ ទម្លាប់អានសៀវភៅរបស់សិស្ស

ផ្នែកនេះបង្ហាញអំពីទម្លាប់អានសៀវភៅទូទៅរបស់សិស្ស ដោយពុំគិតថានៅផ្ទះ ឬនៅសាលាឡើយ។ វារៀបរាប់អំពីលទ្ធផលរកឃើញពាក់ព័ន្ធនឹងភាពញឹកញាប់នៃការអានសៀវភៅរបស់សិស្ស ប្រភេទឯកសារដែលសិស្សចូលចិត្តអាន និងកម្រិតចូលចិត្តនៃការអានសៀវភៅរបស់ពួកគេ។ សម្រាប់អថេរទាំងនេះ ចម្លើយត្រូវបានបែងចែកទៅតាមភេទ និងបទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងការអនុវត្តការអានរបស់គ្រួសារនៅផ្ទះដើម្បីវិភាគអំពីភាពខុសគ្នាខ្លាំងរវាងទម្លាប់របស់សិស្សប្រុស និងសិស្សស្រី និងសិស្សដែលមាន ឬគ្មានការគាំទ្រពីគ្រួសារចំពោះការអានសៀវភៅកាលនៅពីតូច។

## ៣.៤.១ ការអានជាផ្នែកមួយនៃសកម្មភាពកម្សាន្តក្នុងពេលទំនេររបស់សិស្ស

សិស្សត្រូវបានសាកសួរអំពីសកម្មភាពផ្សេងដែលខ្លួនបានធ្វើនៅពេលទំនេរ។ ការស្ទង់មតិបានបង្ហាញថា សិស្សចំនួន 82% បានរៀបរាប់ថា ការ "អានសៀវភៅ" គឺជាសកម្មភាពដែលខ្លួនធ្វើនៅពេលទំនេរ។ សកម្មភាពផ្សេងៗទៀតដែលបានលើកឡើងគឺ ការប្រាស្រ័យទាក់ទងជាមួយសហគមន៍ ឬសិស្ស (25.7%) លេងកីឡា (23.7%) និងចំណាយពេលជាមួយគ្រួសារ (23%)។

*ក្រាហ្វ 11៖ សកម្មភាពកម្សាន្តក្នុងពេលទំនេររបស់សិស្សបែងចែកតាមភេទ*



## ៣.៤.២ ឯកសារ និងទីកន្លែងដែលសិស្សចូលចិត្តអាន

ផ្នែកនេះបង្ហាញអំពីចំណង់ចំណូលចិត្តអានសៀវភៅរបស់សិស្ស (ប្រសិនបើមានជម្រើស) រួមទាំងប្រភេទឯកសារ បែបនៃសៀវភៅ ព្រមទាំងប្រធានបទ និងទីកន្លែងដែលសិស្សចូលចិត្តអាន។ សៀវភៅពុម្ពគឺជាសៀវភៅដែលសិស្សចូលចិត្តអានភាគច្រើន (96%) បន្ទាប់មកគឺសៀវភៅរឿង (76%) (ក្រាហ្វ12)។

នៅពេលសិស្សត្រូវបានសាកសួរថាតើ សៀវភៅបែបអ្វីខ្លះដែលពួកគេចូលចិត្តអាន ពួកគេបានឆ្លើយថាសៀវភៅរឿង (74%) និងសៀវភៅពុម្ព (55%) មានតែមួយចំនួនតូចប៉ុណ្ណោះដែលបាននិយាយថារឿងប្រឌិតបែបប្រវត្តិសាស្ត្រ (ក្រាហ្វ 13) ហើយមានចំនួនតិចបំផុតដែលបានលើកឡើងចូលចិត្តប្រភេទសៀវភៅផ្សេងៗទៀត។

*ក្រាហ្វ 12៖ ប្រភេទឯកសារអានផ្សេងៗដែលសិស្សអានជាទូទៅ*




*ក្រាហ្វ 13៖ បែបនៃសៀវភៅដែលសិស្សអានជាទូទៅ*



នៅពេលសិស្សត្រូវបានសាកសួរអំពីប្រធានបទដែលពួកគេចូលចិត្តអាន (ក្នុងចំណោមប្រធានបទដែលដាក់ឲ្យជ្រើសរើស) ប្រធានបទ ភាគច្រើនត្រូវបានជ្រើសរើស លើកលែងតែសៀវភៅស្តីពីម៉ូតសម្លៀកបំពាក់ កែសម្ផស្ស និងសេដ្ឋកិច្ច (ក្រាហ្វ 14)។ ប្រធានបទទូទៅបំផុតដែលសិស្សបានរៀបរាប់ថាចូលចិត្តអានគឺ សុខភាព កីឡា វិទ្យាសាស្ត្រ កសិកម្ម និងប្រវត្តិសាស្ត្រ។ ការស្ទង់មតិក៏បានបង្ហាញផងដែរថា សិស្សស្រីចូលចិត្តអានសៀវភៅអំពីបញ្ហាសុខភាពជាងសិស្សប្រុស ចំណែកសិស្សប្រុស ចូលចិត្តអានសៀវភៅកីឡាជាងសិស្សស្រី ។

*ក្រាហ្វ 14៖ ប្រធានបទដែលសិស្សចូលចិត្តអាន*




នៅពេលត្រូវបានផ្តល់ជម្រើសអំពីឯកសារអាន សិស្សជាច្រើនបានបង្ហាញចំណាប់អារម្មណ៍ក្នុងការអានសៀវភៅផ្សេងៗទៀត ក្រៅពីសៀវភៅពុម្ព និងសៀវភៅរឿង ដែលពួកគេតែងតែអាចរកបាន។ លទ្ធផលស្ទង់មតិរបស់ WV នេះ បានបង្ហាញច្បាស់ថា សិស្សអាចរកបានឯកសារដែលខ្លួនចិត្តអានបានតិចតួចប៉ុណ្ណោះ។

*ក្រាហ្វ 15៖ សៀវភៅដែលសិស្សចូលចិត្តអានពេលផ្តល់ជម្រើស បែងចែកតាមភេទ*



ពាក់ព័ន្ធនឹងទីកន្លែងអានវិញ ការសិក្សាបានបង្ហាញថា ផ្ទះគឺជាទីកន្លែងដែលសិស្សចូលចិត្តអានជាងគេបំផុត (43%)។ ទីកន្លែងបន្ទាប់គឺ បណ្ណាល័យសាលា (37%)។ សិស្សភាគតិច (11%) ចូលចិត្តអាននៅក្នុងបរិវេណសាលាដែលមិនមែនក្នុងបណ្ណាល័យ។

*ក្រាហ្វ 16៖ ទីកន្លែងដែលសិស្សចូលចិត្តអាន*




## ៣.៤.៣ ភាពញឹកញាប់នៃការអាន (មិនមែនសៀវភៅពុម្ព) និងទំនាក់ទំនងជាមួយអថេរផ្សេងៗទៀត

ដើម្បីកំណត់ភាពញឹកញាប់នៃការអាន ការស្ទង់មតិបានបញ្ចូលសំណួរអំពី 1) ចំនួនដងដែលសិស្សអានក្នុងមួយសប្តាហ៍ 2) រយៈពេលដែលពួកគេបានចំណាយលើការអានក្នុងមួយសប្តាហ៍ និង 3) ចំនួនសៀវភៅដែលពួកគេអានក្នុងមួយឆ្នាំ។ សំណួរសុទ្ធតែបានបញ្ជាក់ថា សិស្សមិនគួររាប់បញ្ចូលនូវពេលវេលាដែលចំណាយលើការអានសៀវភៅពុម្ពរបស់សាលាឡើយ។

ចំនួនដងដែលសិស្សអានក្នុងមួយសប្តាហ៍មានចាប់ពីមួយដង រហូតដល់ 22 ដងក្នុងមួយសប្តាហ៍។ ទោះបីយ៉ាងណា សិស្សភាគច្រើន (80%) បានរៀបរាប់ការអានចន្លោះពី 2 ទៅ 5 ដងក្នុងមួយសប្តាហ៍ (គិតជាមធ្យមគឺ 3ដងក្នុងមួយសប្តាហ៍)។ សិស្សចំនួន 20% ផ្សេងទៀតនិយាយថាខ្លួនអានចំនួនពី 6 ទៅ 22 ដងក្នុងមួយសប្តាហ៍។ ការស្ទង់មតិបានបង្ហាញថាសិស្សចំនួន 4.6% អានចំនួនតែម្តងក្នុងមួយសប្តាហ៍ 21.5% អានចំនួនពីរដងក្នុងមួយសប្តាហ៍ 24.9%អានចំនួនបីដងក្នុងមួយសប្តាហ៍ 10.8% អានចំនួនបួនដងក្នុងមួយសប្តាហ៍ និង 23.8% អានចំនួន ប្រាំដងក្នុងមួយ សប្តាហ៍។ ក្រាហ្វ 17 បង្ហាញអំពីលទ្ធផលទាំងនេះដែលបែងចែកទៅតាមភេទ។

*ក្រាហ្វ 17៖ ភាពញឹកញាប់នៃការអានសៀវភៅក្នុងមួយសប្តាហ៍ដែលសិស្សបានរាយការណ៍ និងបែងចែកទៅតាមភេទ*




បើពិនិត្យមើលរយៈពេលដែលបានចំណាយលើការអានក្នុងមួយសប្តាហ៍បានបង្ហាញថា សិស្សលើសពី 72% បានបញ្ជាក់រយៈពេលអានតិចជាងមួយម៉ោង។ បើចែកចំនួននេះក្នុងមួយសប្តាហ៍ 60នាទី ក្នុងរយៈពេល 7ថ្ងៃ បង្ហាញថា សិស្សភាគច្រើនចំណាយពេលតិចជាង10នាទី ក្នុងមួយថ្ងៃដើម្បីអានឯកសារផ្សេងៗទៀតក្រៅពីសៀវភៅពុម្ព។

*ក្រាហ្វ 18៖ រយៈពេលដែលសិស្សបានអានក្នុងមួយសប្តាហ៍ ដែលបែងចែកទៅតាមភេទ*



ចំនួនសៀវភៅគិតជាមធ្យមដែលបានអានក្រៅពីសៀវភៅពុម្ព មានចំនួន12 ក្បាល ក្នុងរយៈពេល 12 ខែ ចុងក្រោយ។ ទោះជាយ៉ាងនេះក្តី សិស្សចំនួនតិចជាង 10% បាននិយាយថាពួកគេអានចន្លោះពី 21 ទៅ 200 ក្បាល ចំណែកសិស្សចំនួនជិតពាក់កណ្តាល (44%) និយាយថាចន្លោះពី 1 ទៅ 5 ក្បាល។ ការសិក្សាមិនបានស្រាវជ្រាវអំពីភាពស្មុគស្មាញនៃឯកសារអានរបស់ពួកគេទេ ហើយលទ្ធផលហាក់ដូចជាមិនមានភាពខុសគ្នាខ្លាំងរវាងភេទឡើយ។

*ក្រាហ្វ 19៖ ចំនួនសៀវភៅដែលសិស្សបានអាននៅក្នុងរយៈពេល 12 ខែចុងក្រោយ*




ការសិក្សាមិនបានរកឃើញភាពខុសគ្នាខ្លាំង ឬទំនាក់ទំនងរវាងភេទ ឬកម្រិតថ្នាក់ពាក់ព័ន្ធនឹង 1) ចំនួនដងដែលសិស្សបានអានក្នុងមួយសប្តាហ៍ 2) រយៈពេលដែលបានចំណាយលើការអានក្នុងមួយសប្តាហ៍ឬ 3) ចំនួនសៀវភៅដែលបានអានក្នុងមួយឆ្នាំ។ ប៉ុន្តែ ទំនាក់ទំនងត្រូវបានរកឃើញរវាងចំនួនសៀវភៅដែលសិស្សបានអាន និងថាតើសាលាមានបណ្ណាល័យ ឬអត់ ($p=0.05$)។ នៅក្នុងសាលាដែលមានបណ្ណាល័យ ចំនួនសៀវភៅដែលសិស្សបានអានក្នុងរយៈពេលមួយឆ្នាំមានកម្រិតខ្ពស់ជាងសាលាដែលគ្មានបណ្ណាល័យ។

លទ្ធផលក៏បានបង្ហាញផងដែរថា ទម្លាប់វិជ្ជមានរបស់គ្រួសារក្នុងការ 1) លើកទឹកចិត្តសិស្សឲ្យអានសៀវភៅតាំងពីតូច (ដោយមាន 94.4% បានឆ្លើយថា “បាទ/ចាស”) និង 2) អានសៀវភៅ ឬសៀវភៅរឿងឲ្យក្មេងស្តាប់កាលនៅតូច (74.4% បានឆ្លើយថា “បាទ/ចាស”) ពិតជាមានទំនាក់ទំនងយ៉ាងខ្លាំងជាមួយទម្លាប់អានរបស់សិស្សនាពេលបច្ចុប្បន្ន។ សំណួរទាំងពីរត្រូវបានធ្វើតេស្តធៀបនឹងចំនួនដងដែលសិស្សបានអានក្នុងមួយសប្តាហ៍ នៅអំឡុងពេលបច្ចុប្បន្ន (ដោយប្រើប្រាស់តេស្តស្ថិតិ t-test) និងបានបង្ហាញអំពីភាពខុសគ្នាខ្លាំងសម្រាប់សំណួរទាំងពីរ ($p<.05$)។ ការធ្វើតេស្តបានបង្ហាញថា សិស្សដែលមានសមាជិកគ្រួសារបានលើកទឹកចិត្តខ្លួនឲ្យអានសៀវភៅ និង/ឬបានអានសៀវភៅរឿង និងសៀវភៅផ្សេងៗឮៗឲ្យខ្លួនស្តាប់ អានច្រើនដងក្នុងមួយសប្តាហ៍នាពេលបច្ចុប្បន្ន ជាងសិស្សដែលគ្មានសមាជិកគ្រួសារអនុវត្តដូច្នេះ។

## ៣.៤.៤ ទំនាក់ទំនងនៃការចូលចិត្តអានសៀវភៅជាមួយអថេរផ្សេងៗទៀត

ការស្ទង់មតិបានបង្ហាញថា សិស្សចំនួន 32.7% បានរៀបរាប់ថាខ្លួនចូលចិត្តអានសៀវភៅខ្លាំងណាស់ ចំនួន 36.5% ចូលចិត្តខ្លាំង ចំណែក 27.2% ចូលចិត្តដែរ និងចំនួន 4% មិនសូវចូលចិត្ត ឬមិនចូលចិត្តតែម្តង។ បើបែងចែកតាមភេទ (ក្រាហ្វ 20) លទ្ធផលបង្ហាញថា សិស្សស្រីចូលចិត្តអានសៀវភៅជាងសិស្សប្រុស ដោយមានសិស្សស្រីចំនួន 40% និយាយថា ខ្លួនចូលចិត្តអានសៀវភៅ "ខ្លាំងណាស់" ឬ "ខ្លាំង" បើប្រៀបធៀបជាមួយសិស្សប្រុសដែលមានចំនួនតែ 30% ប៉ុណ្ណោះ។

*ក្រាហ្វ 20៖ ការចូលចិត្តអានសៀវភៅរបស់សិស្ស បែងចែកតាមភេទ*




ដើម្បីផ្តល់សុពលភាពដល់លទ្ធផល ដែលថា សិស្សស្រីទំនងជាចូលចិត្តអានជាងសិស្សប្រុស ការធ្វើតេស្ត t-test ត្រូវបានធ្វើឡើងដើម្បីពិនិត្យថាតើមានភាពខុសគ្នាខ្លាំងរវាងភេទ (ប្រុស និងស្រី) ពាក់ព័ន្ធនឹងកម្រិតនៃការចូលចិត្តអានដែរឬទេ។ ការធ្វើតេស្តបានបង្ហាញអំពីភាពខុសគ្នាខ្លាំងផ្នែកស្ថិតិរវាងសិស្សប្រុស និងសិស្សស្រី ($p < .001$)។ សិស្សស្រីបានបញ្ជាក់អំពីកម្រិតនៃការចូលចិត្តអានខ្ពស់ខ្លាំងជាងសិស្សប្រុស។

ការវិភាគក៏បានបង្ហាញផងដែរអំពីភាពខុសគ្នាដ៏គួរឲ្យកត់សម្គាល់ រវាងការចូលចិត្តអានរបស់សិស្សនិងទម្លាប់អានវិជ្ជមាននៅក្នុងគ្រួសារ (ឧទាហរណ៍ សមាជិកគ្រួសារតែងតែអានសៀវភៅរឿង ឬសៀវភៅផ្សេងៗឲ្យសិស្សស្តាប់នៅពីតូច) បើប្រៀបធៀបជាមួយសិស្សដែលពុំធ្លាប់មានគ្រួសារអនុវត្តដូច្នេះ។ ការធ្វើតេស្តបានបង្ហាញ ទំនាក់ទំនងដ៏គួរឲ្យកត់សម្គាល់ផ្នែកស្ថិតិមួយរវាងសិស្សដែលមានគ្រួសារមានទម្លាប់នៃការអានល្អ និងគ្រួសារដែលគ្មានទម្លាប់នៃការអានល្អ ($p < .001$)។ សិស្សដែលមានសមាជិកគ្រួសារអានសៀវភៅឲ្យខ្លួនស្តាប់បានរៀបរាប់អំពីការចូលចិត្តអានក្នុងកម្រិតខ្ពស់ខ្លាំងជាងសិស្សដែលមិនមានសមាជិកគ្រួសារមានទម្លាប់ដូច្នោះ។

ជាចុងក្រោយ ការធ្វើតេស្តស្ថិតិបានបង្ហាញអំពីទំនាក់ទំនងដ៏វិជ្ជមានរវាងកម្រិតនៃការយល់ឃើញលើសមត្ថភាពអានរបស់សិស្ស និងការចូលចិត្តអានរបស់ពួកគេ ពោលគឺសិស្សដែលគិតថាសមត្ថភាពអានរបស់ខ្លួនមានកម្រិតទាបគឺមិនសូវចូលចិត្តអានឡើយ ផ្ទុយទៅវិញ សិស្សដែលយល់ថាខ្លួនឯងមានសមត្ថភាពអានកាន់តែខ្ពស់ សិស្សទាំងនោះក៏កាន់តែចូលចិត្តអានកាន់តែខ្លាំងដែរ។

*ក្រាហ្វ 21៖ទំនាក់ទំនងរវាងការយល់ឃើញលើសមត្ថភាពអាន និងការចូលចិត្តអានរបស់សិស្ស*




## ៣.៤.៥ ការជំរុញទឹកចិត្តក្នុងការអាន

ពេល សួរថាហេតុអ្វីបានជាពួកគេអានសៀវភៅ សិស្សបានផ្តល់ចម្លើយផ្សេងៗគ្នា សរុបចំនួន 966ចម្លើយ។ ចម្លើយជាច្រើនបំផុតគឺដើម្បីទទួលបានចំណេះដឹងទូទៅ (31.5%) បន្ទាប់មកគឺការចង់ស្វែងយល់មេរៀននៅសាលា (20.6%) បន្ទាប់មកទៀតគឺដើម្បីកម្សាន្ត ឬលំហែកាយ (17.6%)។

*ក្រាហ្វ 22៖ មូលហេតុដែលសិស្សអានសៀវភៅ បែងចែកតាមភេទ*



ពេលត្រូវបានសួរថាតើកត្តាអ្វីដែលធ្វើឲ្យសិស្សចង់អានច្រើនជាងមុន ចម្លើយទូទៅបំផុតគឺ ប្រសិនបើពួកគេមានអារម្មណ៍រីករាយជាមួយនឹងការអានច្រើនជាងមុន (43%) ប្រសិនបើសៀវភៅស្រួលអាន (36%) និងប្រសិនបើសៀវភៅមានរូបភាព (37%)។ កត្តាជំរុញផ្សេងៗទៀតរួមមាន ប្រសិនបើសិស្សមានភាពងាយស្រួលក្នុងការរកឯកសារអានជាងមុន (16%) ប្រសិនបើមានអ្នកជួយខ្លួនក្នុងការអាន (14%) និងប្រសិនបើខ្លួនអានជាក្រុម (12%)។

*ក្រាហ្វ 23៖ កត្តាដែលនឹងជួយសិស្សឲ្យអានបានច្រើនជាងមុន*



# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## សង្ខេបលទ្ធផល

ការសិក្សាទៅលើបរិយាកាស និងទម្លាប់នៃការអានរបស់អង្គការទស្សនៈពិភពលោកបានបង្ហាញពី ការអនុវត្ត និងបរិយាកាស ដែលមានឥទ្ធិពលទៅលើការអានរបស់សិស្សនៅក្នុងប្រទេសកម្ពុជា។ លទ្ធផលបានផ្តល់សុពលភាព និងបំពេញបន្ថែមទៅលើ ចំណេះដឹងដែលមានស្រាប់មួយចំនួន ប៉ុន្តែក៏ប្រឆាំងនឹងការសន្មត់ជាទូទៅមួយចំនួនផងដែរ ដែលចំណុចទាំងពីរនេះសុទ្ធតែមាន សារសំខាន់ចំពោះការលម្អកម្មវិធីអប់រំនៅក្នុងប្រទេសទាំងមូល។

ការសិក្សានេះមានលក្ខណៈខុសពីការស្រាវជ្រាវផ្សេងទៀត ដោយសារការសិក្សានេះផ្តោតទៅលើកត្តាផ្សេងៗនៃទម្លាប់ដែលអាចរួម ចំណែកធ្វើឲ្យមានភាពស្ទាត់ជំនាញក្នុងការអាន និងផ្អែកទៅលើការរៀបរាប់និងការយល់ឃើញរបស់សិស្សផ្ទាល់ ជាជាងប្រៀបធៀប ភ្លាមៗទិន្នន័យបែបគុណភាពទៅនឹងស្តង់ដារអប់រំបែបបរិមាណ ។ ឧទាហរណ៍ ជាទូទៅកម្មវិធីអប់រំព្យាយាមស្វែងរកកម្រិត ដែល គ្រួសារលើកទឹកចិត្តកុមារឲ្យចូលរៀននៅសាលា ប៉ុន្តែជាទូទៅវាជាប់ពាក់ព័ន្ធទៅនឹងការលើកកម្ពស់ការមករៀនឲ្យបានទៀងទាត់ និងការកាត់បន្ថយអត្រាបោះបង់ការសិក្សារបស់សិស្សប៉ុណ្ណោះ។ ផ្ទុយពីនេះ ការសិក្សានេះស្វែងយល់អំពីឥទ្ធិពលនៃការលើកទឹកចិត្ត របស់គ្រួសារដែលមិនត្រឹមតែពាក់ព័ន្ធនឹងការមករៀននៅសាលានោះទេ ប៉ុន្តែក៏ពាក់ព័ន្ធនឹងទម្លាប់នៃការសិក្សាព្រមទាំងការអានរបស់ សិស្សផងដែរ។

ដូច្នេះ សេចក្តីសន្និដ្ឋានផ្តោតខ្លាំងទៅលើថា តើទម្លាប់ផ្សេងៗគ្នា ( ទាំងសិស្ស និងគ្រួសារ ) អាចមានឥទ្ធិពលទៅលើសិស្សយ៉ាង ដូចម្តេចខ្លះ ជាពិសេស ការចូលចិត្តអានសៀវភៅ និងការយល់ឃើញលើសមត្ថភាព អានរបស់សិស្ស ព្រមទាំងទំនាក់ទំនងផ្សេងៗ ទៀតដែលអាចរកឃើញលើភាពអាចរកបាននៃសេវាបណ្ណាល័យនៅតាមសាលាផងដែរ។

## ការយល់ឃើញលើសមត្ថភាពអានរបស់សិស្ស

ការស្ទង់មតិបានបង្ហាញថា កុមារចំនួន 64.7% បានរៀបរាប់ពីភាពស្ទាត់ជំនាញក្នុងការអានរបស់ខ្លួនថា “ល្អណាស់” “ល្អបង្គួរ” និង “ល្អ”។ ការយល់ឃើញនេះហាក់ មិនស៊ីគ្នាជាមួយនឹងអត្រាអក្ខរកម្មដែលគេតែងតែយោងនៅក្នុងប្រទេសកម្ពុជាឡើយ។ ទិន្នន័យពីគម្រោងផ្ទាល់របស់អង្គការទស្សនៈពិភពលោក ( និងការវាយតម្លៃថ្នាក់ជាតិទៅលើស្តង់ដារអំណានផ្សេងៗទៀត ) បង្ហាញថា មានកុមារថ្នាក់ទី 6ត្រឹមតែ 50% ប៉ុណ្ណោះដែលចេះអានអក្សរ។

ទោះបីយ៉ាងណា អ្នកឯកទេសអក្ខរភាពបានលើកឡើងថា ការយល់ឃើញរបស់កុមារ ( child’s self perception ឬ ability self-concept ) នឹងមានឥទ្ធិពលទៅលើការជ្រើសរើស និងការប្តេជ្ញាចិត្តរបស់សិស្សលើសកម្មភាពផ្សេងៗ ដែលរួមមានការអានជាដើម។ កុមារកាន់ តែចង់ធ្វើសកម្មភាពណាមួយដែលខ្លួនចូលចិត្ត និងគិតថាគេប៉ិនប្រសប់។ ដូច្នេះ ខណៈដែលលទ្ធផលលើការយល់ឃើញរបស់លើ សមត្ថភាពអានរបស់សិស្សអាចចោទជាបញ្ហា វាមានសារៈសំខាន់ដែលត្រូវទទួលស្គាល់ និងដោះស្រាយក្នុងកម្មវិធីអប់រំ។ បើយោងតាមការយល់ដឹងរបស់អង្គការទស្សនៈពិភពលោក លើបណ្ណាល័យនៅតាមសាលាគោលដៅ វាហាក់ដូចជាពុំមានទំនាក់ ទំនងរវាងការយល់ឃើញរបស់កុមារលើសមត្ថភាព អានរបស់ពួកគេ ទៅនឹងភាពអាចរកបាននៃធនធានបណ្ណាល័យ (រួមទាំងម៉ោង បើកបណ្ណាល័យ បណ្ណារក្សដែលមានជំនាញ ឬចំនួនសៀវភៅក្នុងបណ្ណាល័យ ) ឡើយ។ នេះបង្ហាញថា ការលើកទឹកចិត្តលើជំនាញ អានដែលកុមារទទួលបាន គឺមិនមែនទទួល [ជាចម្បង] បានមកពីបណ្ណាល័យសាលាទេ។

## បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសអាននៅផ្ទះ

ភ័ស្តុតាងជាសកលបង្ហាញថា មានទំនាក់ទំនងដ៏រឹងមាំរវាងបរិយាកាសដែលសម្បូរឯកសារអាន និងអត្រាអក្ខរកម្ម។ នៅក្នុងប្រទេសកម្ពុជា ដោយសារមានផ្ទះចំនួនតិចតួចដែលមានធនធានសម្រាប់អាន ទើបសាលានិងបណ្ណាល័យបានក្លាយជាប្រភពធនធានសំខាន់ដើម្បីបំពេញភាពខ្វះខាតនៅផ្ទះ។

ចំនួនសិស្សដែលបាននិយាយថាមានសមាជិកគ្រួសារដែលអាន ដែលជួយគាំទ្រដល់ការអាន ( ដូចជាជួយដល់ការធ្វើកិច្ចការសាលា ) ឬដែលអានឮៗឲ្យកុមារស្តាប់ គឺជាលទ្ធផលគួរជាទីលើកទឹកចិត្ត ដែលបង្ហាញអំពីទំនាក់ទំនងរឹងមាំរវាងការគាំទ្ររបស់គ្រួសារ និងជំនាញអក្ខរភាព។ លទ្ធផលបានបង្ហាញពីបរិយាកាសគាំទ្រការអាននៅផ្ទះច្រើនជាងការរំពឹងទុកបើផ្អែកលើទិន្នន័យ និងការវាយតម្លៃនៅក្នុងគម្រោងពីមុនៗ ( ទិន្នន័យមិនបានផ្សព្វផ្សាយរបស់ WV )។ ទោះជាយ៉ាងនេះក្តី បញ្ហាកំហិតចំពោះការអាននៅផ្ទះត្រូវបានរកឃើញថា ដោយសារកង្វះខាតឯកសារ និងឯកសារមិនសូវសម្បូរបែប ពោលគឺសិស្សជាច្រើនបាននិយាយថា ខ្លួនមាន តែសៀវភៅពុម្ព និងសៀវភៅរឿងតែប៉ុណ្ណោះនៅផ្ទះ ដោយមិនសូវទទួលបានឯកសារអានផ្សេងទៀតដែលខ្លួនចាប់អារម្មណ៍ឡើយ។

ការសិក្សាបានគូសបញ្ជាក់ថា ការអនុវត្តល្អនៅផ្ទះ ( ទម្លាប់អានរបស់គ្រួសារ ) ទាំងបច្ចុប្បន្ន និងនៅពេលកុមារនៅតូច( ដូចជាការអានសៀវភៅរឿងឲ្យកុមារស្តាប់ ការលើកទឹកចិត្តកុមារឲ្យអានសៀវភៅ និងការជួយក្នុងការធ្វើកិច្ចការសាលា ) អាចមានឥទ្ធិពលទៅលើ ការចូលចិត្តអាន និងភាពញឹកញាប់នៃការអានរបស់កុមារ។ ទាំងការអានឲ្យកុមារស្តាប់នៅវ័យកុមារភាព និងការលើកទឹកចិត្តឲ្យកុមារអាននៅវ័យកុមារភាពធ្វើឲ្យសិស្សអានកាន់តែញឹកញាប់ និងចូលចិត្តអានកាន់តែខ្លាំងនាពេលបច្ចុប្បន្ន។ លទ្ធផលទាំងនេះផ្តល់នូវភ័ស្តុតាងសំខាន់ថា ការលើកកម្ពស់ទម្លាប់នៃការអាននៅក្នុងគ្រួសារគួរតែជាសមាសធាតុសំខាន់នៃកម្មវិធីអក្ខរកម្ម។ វាជាការចាំបាច់ដែលឪពុកម្តាយ និងអ្នកថែទាំកុមារទាំងអស់ត្រូវយល់ដឹងអំពីគុណតម្លៃនៃការអាន និងការបង្កើតបរិយាសអំណោយផលសម្រាប់ការអាន និងសម្រាប់ការអប់រំរបស់កូន។

ទោះបីយ៉ាងណា ការសិក្សាក៏បានបង្ហាញពីលទ្ធភាពមានកម្រិតក្នុងការរកបានឯកសារអានដែលសម្បូរបែបនៅផ្ទះ ( និងនៅសាលា )។ ប្រសិនបើចំណុចនេះត្រូវបានដោះស្រាយ ព្រមទាំងការអានឲ្យកុមារតូចស្តាប់ និងការលើកទឹកចិត្តកុមារឲ្យអានសៀវភៅ ឥទ្ធិពលទៅលើទម្លាប់នៃការអាន និងកម្រិតអក្ខរកម្ម នឹងមានការកែល្អប្រសើរជាបន្តបន្ទាប់។

## បទពិសោធន៍របស់សិស្សពាក់ព័ន្ធនឹងបរិយាកាសនៃការអាននៅតាមសាលា ជាពិសេសបណ្ណាល័យ

ប្រទេសកម្ពុជាបានសម្រេចគួរឲ្យកត់សម្គាល់លើការលើកកម្ពស់គុណភាពវិស័យអប់រំសាធារណៈរបស់ខ្លួន រួមទាំងគោលនយោបាយ ច្បាប់ និងគោលការណ៍ណែនាំដែលធ្វើឲ្យសិស្សអាចចូលរៀនសាលាបឋមសិក្សាបានកាន់តែងាយស្រួលនៅទូទាំងប្រទេស។ ទោះជាយ៉ាងនេះក្តី ការទៅសាលារៀនដែលមានមានអគារ និងថ្នាក់រៀន មិនប្រាកដថាសិស្សទទួលបានចំណេះដឹងនោះនៅឡើយទេ។

នៅក្នុងការសិក្សាអំពីបរិយាកាស និងទម្លាប់នៃការអាននេះ ហាក់ដូចជាបានបង្ហាញថាមានការប្រើប្រាស់បណ្ណាល័យបានទៀងទាត់ (សិស្សភាគច្រើនបានរៀបរាប់ថាចូលបណ្ណាល័យយ៉ាងតិចម្តងក្នុងមួយសប្តាហ៍)។ ប៉ុន្តែ រយៈពេលដែលសិស្សបានចំណាយនៅក្នុងបណ្ណាល័យសម្រាប់ការចូលម្តងគឺខ្លីណាស់ ដែលសិស្ស ប្រហែលជាពាក់កណ្តាលបានចំណាយរយៈពេល 10 នាទី ឬតិចជាងនេះនៅពេលចូលបណ្ណាល័យម្តងៗ ដែលជាបញ្ហាកំហិតទៅលើគុណភាព និងភាពស៊ីជម្រៅនៃ "ការប្រើប្រាស់" ដែលពួកគេអាចទទួលបាន។

បើយោងតាមលទ្ធផលការសិក្សា កត្តារួមចំណែកផ្សេងៗលើបញ្ហានេះ គឺអាចមកពីចំនួនម៉ោងដែលបណ្ណាល័យបើកនៅមានកម្រិត កង្វះខាតឯកសារដែលសម្បូរបែប (ដែលភាគច្រើនជាសៀវភៅពុម្ព និងមានសៀវភៅរឿង ឬសៀវភៅអំពីប្រធានបទផ្សេងៗទៀតតែមួយចំនួនតូច) ឬក៏អាចមកពីអនាម័យ និងទីតាំងបណ្ណាល័យផងដែរ (បណ្ណាល័យមួយចំនួនស្ថិតនៅជ្រុងថ្នាក់រៀន ឬទីចាត់ការ)។

លទ្ធផលរកឃើញសំខាន់មួយផ្សេងទៀតគឺ មានសិស្ស តែ 54.8% ប៉ុណ្ណោះដែលបានខ្ចីសៀវភៅពីបណ្ណាល័យចាប់តាំងពីដើមឆ្នាំសិក្សា នេះគឺមានសិស្សចំនួនជិតពាក់កណ្តាល (45.2%) មិនដែលបានខ្ចីអ្វីទាល់តែសោះពីបណ្ណាល័យនៅក្នុងឆ្នាំនេះ ។ ចំណុចនេះបង្ហាញអំពីការប្រើប្រាស់បណ្ណាល័យមិនទាន់អស់លទ្ធភាព និងគាំទ្រដោយអង្គហេតុដែលថា "សេវាខ្ចីសៀវភៅ" គឺជាចំណុចនៃការស្ទាបស្ទង់ការពេញចិត្តសេវាបណ្ណាល័យតែមួយគត់ដែលទទួលបានការវាយតម្លៃថា "មិនសូវពេញចិត្ត" ច្រើនជាងគេ។ សិស្សក៏ហាក់ដូចជាមិនសូវចង់ខ្ចីសៀវភៅយកមកអាននៅផ្ទះផងដែរដោយសារពួកគេខ្លាចធ្វើឲ្យខូច សៀវភៅ ដែលមានចំនួនតិចស្រាប់ (ជាការយល់ឃើញមួយដូចគ្រូដែរគឺខ្លាចបាត់បង់ ឬខូចខាតសៀវភៅដែលមានចំនួនតិចស្រាប់។)

ខណៈដែលបរិយាកាសអាននៅសាលាមិនសំដៅតែលើ បណ្ណាល័យតែមួយមុខនោះ បញ្ហាជាច្រើនដែល (អាច) ធ្វើឲ្យសិស្សមិនចង់អានសៀវភៅនៅសាលាក៏ជាប់ពាក់ព័ន្ធទៅនឹងបញ្ហាបណ្ណាល័យមានស្តង់ដារគុណភាពទាប ដូចមានចែងនៅក្នុងគោលនយោបាយស្តីពី "ស្តង់ដារ បណ្ណាល័យបឋមសិក្សា" (2011)។ សំណូមពរភាគច្រើនរបស់សិស្សក្នុងការជួយលើកកម្ពស់បរិយាកាសអាននៅសាលាពាក់ព័ន្ធនឹងការបំពេញឲ្យបានតាមស្តង់ដារបណ្ណាល័យទាំងនេះ។ ដូច្នេះការវិនិយោគបន្ថែម និងការគាំទ្រសាលាឲ្យសម្រេចបានតាមស្តង់ដារទាំងនេះទំនងជាអាចធ្វើឲ្យទម្លាប់អានសៀវភៅរបស់សិស្សកាន់តែល្អប្រសើរជាងមុន។

## ចំណង់ចំណូលចិត្ត និងទម្លាប់នៃការអានសៀវភៅទូទៅរបស់សិស្ស

ទម្លាប់អានសៀវភៅជាទូទៅរបស់សិស្សគឺមានភាពល្អ បើសំដៅទៅលើភាពញឹកញាប់នៃការអាន។ ប៉ុន្តែរយៈពេលដែលសិស្សអានគឺជាកង្វល់ដ៏ធំមួយដោយសារសិស្សស្ទើរតែទាំងអស់បានរៀបរាប់អំពីការអានតិចជាងមួយម៉ោងក្នុងមួយសប្តាហ៍ ហើយចំនួនសៀវភៅដែលបានអាននៅក្នុងរយៈពេល 12ខែ ចុងក្រោយក៏មានកម្រិតទាបខ្លាំងដែរ។

ដោយសារសិស្សមានកង្វះខាតផ្នែកឯកសារអានដែលសម្បូរបែបទាំងនៅបណ្ណាល័យ និងនៅផ្ទះ សិស្សភាគច្រើនបានអានតែសៀវភៅពុម្ព និងសៀវភៅរឿងប៉ុណ្ណោះ។ ទោះបីជាយ៉ាងណា សិស្សជាច្រើនបានសំដែងថា ខ្លួនចង់អានសៀវភៅប្រភេទផ្សេងៗគ្នាជាច្រើន និងអំពីប្រធានបទដែលសម្បូរបែបផងដែរ។ ដូច្នេះការបន្ថែមប្រភេទ និងខ្លឹមសារសៀវភៅសម្រាប់សិស្សអាចមានឥទ្ធិពលជាវិជ្ជមានទៅលើទម្លាប់នៃការអានរបស់សិស្ស និងជួយជំរុញសិស្សឲ្យអានកាន់តែញឹកញាប់ និងកាន់តែយូរ។ ការអនុវត្តទៅលើការអានទាំងនេះមានសារៈសំខាន់ក្នុងការពង្រឹងជំនាញអាន និងអាចឲ្យកុមារអភិវឌ្ឍពីការ "រៀនអាន" (រៀនរបៀបអាន) ទៅជា "អានដើម្បីរៀន" (អានដើម្បីរៀនអំពីមុខវិជ្ជាអ្វីមួយដើម្បីបង្កើនចំណេះដឹង ឬជំនាញ)។

# អនុសាសន៍

អនុសាសន៍ពីការស្ទង់មតិលើបរិយាកាស និងទម្លាប់នៃការអានផ្តោតទាំងស្រុងទៅលើថាតើទម្លាប់នៃការអានរបស់សិស្សអាចត្រូវបានគាំទ្រ និងកែលម្អយ៉ាងដូចម្តេច។ លទ្ធផលរកឃើញ និងការសន្និដ្ឋានបង្ហាញថា តាមរយៈការលើកទឹកចិត្តកុមារឲ្យអានតាំងពីតូច ការអានឮៗឲ្យកុមារស្តាប់នៅវ័យកុមារភាព ការផ្តល់ឯកសារអានសម្បូរបែបនៅផ្ទះ និងនៅសាលា ព្រមទាំងការលើកកម្ពស់សេវាបណ្ណាល័យ នោះចំណូលចិត្តក្នុងការអាន និងការយល់ឃើញលើសមត្ថភាពអានរបស់ខ្លួន នឹងមានការកើនឡើង។ ប្រសិនបើសិស្សប្រើប្រាស់ជំនាញអានដែលមានស្រាប់ដើម្បីអានកាន់តែញឹកញាប់ ពួកគេទំនងជាអាចបង្កើនជំនាញរបស់ខ្លួនកាន់តែប្រសើរ។

អនុសាសន៍ខាងក្រោមសំដៅដល់ភាគីពាក់ព័ន្ធសំខាន់ៗ ប៉ុន្តែភាគច្រើនក៏មានសារៈសំខាន់ចំពោះអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល (NGO) ដែលគាំទ្រ និងអនុវត្តគម្រោងផ្តោតលើការលើកកម្ពស់លទ្ធផលអប់រំផងដែរ។ កម្មវិធីទាំងនេះគួរពិចារណាទៅលើរបៀបដែលខ្លួនអាចអនុវត្ត ឬគាំទ្រ ការបំពេញនូវអនុសាសន៍ទាំងនេះផងដែរ។

## អនុសាសន៍សម្រាប់ក្រសួងអប់រំ យុវជន និងកីឡា (កអយក):

- គួរធានាថាមានបណ្ណារក្សគ្រប់គ្រាន់នៅតាមសាលាដោយផ្អែកលើម៉ោងបង្រៀនរបស់សាលា ដើម្បីធានាថាបណ្ណាល័យបើកនិងត្រូវបានប្រើប្រាស់សម្រាប់សិស្សចូលអានបាន។
- គួរវិនិយោគទៅលើការបណ្តុះបណ្តាលជំនាញដល់បណ្ណារក្ស ដើម្បីឲ្យពួកគេអាចមានសមត្ថភាពគ្រប់គ្រងធនធានបណ្ណាល័យកាន់តែប្រសើរឡើង ព្រមទាំងលើកកម្ពស់ប្រសិទ្ធភាពបណ្ណាល័យ ពោលគឺតាមរយៈ បង្កើនការនិទានរឿងឲ្យបានច្រើនជាងមុន ការលើកទឹកចិត្តឲ្យសិស្សខ្ចីសៀវភៅ ការគាំទ្រកុមារក្នុងការប្រើប្រាស់ធនធានបណ្ណាល័យឲ្យបានកាន់តែប្រសើរសម្រាប់ការសិក្សារៀនសូត។
- គួរបង្កើនប្រភេទ ភាពសម្បូរបែប និង បរិមាណឯកសារអានក្នុងបណ្ណាល័យ។ ឯកសារទាំងនេះគួរមានអ្វីផ្សេងក្រៅពីសៀវភៅពុម្ពនិងសៀវភៅរឿង ព្រមទាំងធានាថាបណ្ណារក្សបានលើកទឹកចិត្តសិស្សឲ្យខ្ចីឯកសារអានកាន់តែញឹកញាប់ (ដើម្បីអាននៅផ្ទះ និងនៅក្រៅបណ្ណាល័យ)។
- គួរមានការសម្របសម្រួលកាន់តែល្អប្រសើរជាមួយរចនាសម្ព័ន្ធថ្នាក់ក្រោមជាតិ ដើម្បីធានាថា ការតាមដានសេវាសាលារួមទាំងសេវាបណ្ណាល័យ ត្រូវបានអនុវត្តយ៉ាងទៀងទាត់ និង មានគោលដៅជាក់ស្តែង និងការគាំទ្រដើម្បីឲ្យសាលាសម្រេចនូវគោលការណ៍ណែនាំស្តីពីស្តង់ដារបណ្ណាល័យសម្រាប់សាលាបឋមសិក្សា។

នាពេលបច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា តាមរយៈ កអយក មានស្តង់ដារដ៏ល្អមួយសម្រាប់បណ្ណាល័យ និងបរិយាកាសអាននៅសាលា។ ការបន្តគាំទ្រលើការអនុវត្តប្រកបដោយភាពជោគជ័យនូវស្តង់ដារទាំងនេះនៅតាមសាលា នឹងជួយកែលម្អទម្លាប់អានរបស់សិស្សឲ្យបានកាន់តែល្អប្រសើរថែមមួយកម្រិតទៀត។

## អនុសាសន៍សម្រាប់ឪពុកម្តាយ និងអ្នកថែទាំ៖

- ត្រូវធានាថា កុមារមករៀនទៀងទាត់
- ត្រូវបែងចែកពេលវេលាសម្រាប់អានជាមួយ និងអានឲ្យកុមារស្តាប់ ទាំងមុន និងក្នុងពេលកុមារទៅរៀន។ ការអានជាមួយកុមារអាចធ្វើឲ្យទម្លាប់នៃការអានរបស់កុមារមានភាពប្រសើរឡើង។
- ត្រូវផ្តល់ឯកសារអានឲ្យបានច្រើនតាមដែលអាចធ្វើបានសម្រាប់កុមារអាននៅផ្ទះ (រួមទាំងការលើកទឹកចិត្តកុមារឲ្យខ្ចីសៀវភៅប្រភេទផ្សេងៗពីបណ្ណាល័យសាលា) និងត្រូវធានាថា កុមារមានពេលវេលា និងទីកន្លែងសមរម្យសម្រាប់អាននៅផ្ទះ។
- ត្រូវចូលរួមកាន់តែសកម្មនៅក្នុងជីវិតសិក្សារបស់កុមារ រួមទាំងការចូលរួមនៅក្នុងកិច្ចប្រជុំជាមួយគណៈគ្រប់គ្រងសាលា ព្រឹត្តការណ៍ផ្សេងៗ និងកម្មវិធីដែលអាចជួយលើកកម្ពស់ការគ្រប់គ្រង និងអភិបាលកិច្ចសាលា (រួមទាំងដើម្បីសម្រេចបាននូវស្តង់ដារសេវារដ្ឋាភិបាលផងដែរ)។

## អនុសាសន៍សម្រាប់នាយកសាលា គ្រូបង្រៀន និងគណៈកម្មាធិការទ្រទ្រង់សាលា៖

- នាយកសាលា និងគ្រូបង្រៀនគួរអនុវត្តវិធានការជាក់ស្តែងដែលលើកទឹកចិត្តសិស្សឲ្យចូល ប្រើប្រាស់បណ្ណាល័យសាលាកាន់តែញឹកញាប់ រួមទាំងការចំណាយពេលកាន់តែច្រើននៅក្នុងបណ្ណាល័យ និងការខ្ចីឯកសារអានកាន់តែញឹកញាប់ដើម្បីយកទៅអាននៅក្រៅបណ្ណាល័យ។ វិធានការទាំងនេះអាចរួមមាន ការបើកបណ្ណាល័យឲ្យកាន់តែញឹកញាប់ (ជាពិសេសនៅក្នុងម៉ោងចេញលេង ឬនៅចន្លោះវេនព្រឹក និងវេនល្ងាច) ធ្វើការនិទានរឿង និងអានជាក្រុមឲ្យកាន់តែច្រើននៅក្នុងបណ្ណាល័យ និងណែនាំឯកសារអានថ្មីៗដល់សិស្ស។
- ក្នុងករណីដែលបណ្ណាល័យមានធនធាន មានកម្រិត និងមិនស្របតាមស្តង់ដារជាតិ ត្រូវស្វែងរកការគាំទ្របន្ថែមពីក្រុមប្រឹក្សាឃុំ និងការិយាល័យអប់រំស្រុក ដើម្បីទទួលបានការ គាំទ្រផ្នែកហិរញ្ញវត្ថុដើម្បីអាចកាន់តែខិតជិតស្តង់ដារ។
- ត្រូវបង្កើនការយកចិត្តទុកដាក់ចំពោះសកម្មភាព និងកម្មវិធីផ្សេងៗដែលមានការចូលរួមពីឪពុកម្តាយ និង អ្នកថែទាំសម្រាប់ការអប់រំកូនរបស់ខ្លួន រួមទាំងការលើកទឹកចិត្តឪពុកម្តាយឲ្យអានជាមួយ/អានឲ្យកូនស្តាប់នៅផ្ទះ ការលើកទឹកចិត្តកូនរបស់ខ្លួនឲ្យខ្ចីសៀវភៅពីបណ្ណាល័យ និងការទិញឯកសារអានបន្ថែមទៀត (ក្រៅពីសៀវភៅពុម្ព) សម្រាប់កុមារ អាននៅផ្ទះ។
- ត្រូវធានាឲ្យមានការអនុវត្តពេញលេញនូវ សមាសភាពទី 5 នៃគោលនយោបាយសាលាកុមារមេត្រីដើម្បី “លើកកម្ពស់ទំនាក់ទំនងរវាងសាលារៀននិង សហគមន៍ឲ្យកាន់តែសកម្មខ្លាំងក្លា ដោយប្រែក្លាយសាលារៀនជាមជ្ឈមណ្ឌលរបស់សហគមន៍សម្រាប់អភិវឌ្ឍសហគមន៍និងគ្រួសារ ហើយប្រើប្រាស់ធនធានរបស់សហគមន៍ដើម្បីកិច្ចអភិវឌ្ឍសាលារៀនវិញដែលមានតួនាទីសំខាន់ក្នុងការងារគ្រប់គ្រង” (គោលនយោបាយសាលាកុមារមេត្រី CFS 2007)។

## អនុសាសន៍សម្រាប់សិស្ស៖

- ត្រូវបែងចែកពេលវេលាសម្រាប់ការអាន និងត្រូវអានសៀវភៅឲ្យបានច្រើនប្រភេទ
- ត្រូវអនុវត្តការអានដោយការប្រើបណ្ណាល័យឲ្យបានញឹកញាប់ជាងមុន និងអានសៀវភៅឲ្យបានច្រើនប្រភេទ
- ត្រូវសុំឲ្យឪពុកម្តាយ អ្នកថៃទាំ គ្រូ មិត្តភក្តិ និងបងប្អូនអានជាមួយខ្លួន និងជួយក្នុងការអានពាក្យពិបាកៗ
- ត្រូវចូលរួមនៅក្នុងក្រុមប្រឹក្សាកុមារដើម្បីតស៊ូមតិឲ្យមានការកែលម្អសេវាបណ្ណាល័យសម្រាប់ខ្លួន និងមិត្តភក្តិរបស់ខ្លួន។
- ត្រូវអានជាមួយបងប្អូនប្រុស ស្រីរបស់ខ្លួន និងកុមារផ្សេងទៀតនៅក្នុងភូមិ។

World Vision

PO Box 479, Phnom Penh, Cambodia

Phone +855-23-216 052
Fax +855-23-216 220

contact_cambodia@wvi.org
wvi.org/cambodia

facebook.com/WorldVisionCambodia

@WVCambodia

youtube.com/wvcambodia

Copyright© September 2016 by **World Vision** in Cambodia